**មុណ្ឌ, មុណ្ឌក** គុ. [ មុណ្ឌ+អ ] កាត់, រលីង, ត្រងិល, ត្រងោល ។ **-សមណ** បុំ. សមណៈត្រងោល, ស្រមណ៍ត្រងោល ។ **-បព្វតមត្ថក** បុំ. កំពូលនៃភ្នំត្រងិល ។ **-សិរ** គុ. មានក្បាលត្រងោល ។

**មុត្ត** នបុំ. [ មុច+ត ] មូត្រ, ទឹកមូត្រ, ទឹកនោម; (វិ. **មិហតិ សិញ្ចតីតិ> មុត្តំ**) ។ គុ. ឬ កិ. = រួច, ផុត, ជ្រុះ, ... ។ ឥ. = កែវមុក្តា ។ **-ករីសបុណ្ណ** គុ. ពេញដោយមូត្រនិងករីស ។ **-ចាគ** គុ. អ្នកមានចាគៈផុតហើយ, អ្នកមានការលះរួចហើយ ។ **-ដ្ឋាន** នបុំ. ទីនៃ...រួចហើយ, -ផុតហើយ ។ **-មត្តាវ** គុ. គ្រាន់តែរួចហើយភ្លាម ។

**មុត្តា** ឥ. [ មុច+ត, ចុះអា-ឥ. ] កែវមុក្តា ។ **-ទាមសទិស** គុ. ប្រាកដស្មើដោយកម្រងនៃកែវមុក្តា, -ដោយចង្កោម (ឬភួង) នៃកែវមុក្តា ។ **-ធជ** បុំ. ទង់ជាវិការៈនៃកែវមុក្តា ។ **-យដ្ឋិ** ឥ. ដងជាវិការៈនៃកែវមុក្តា ។

**មុត្តាហារ** បុំ. [ មុត្តា+ហារ ] កែវមុក្តាហារ; កែវមុក្តានិងអង្កាំ ឬអង្កាំជាវិការៈនៃកែវមុក្តា ។

**មុត្តិ** ឥ. [ មុច+តិ ] កិ.រួច; វិ. **មុច្ចនំ> មុត្តិ** ។

**មុទិតមន** គុ. [ មុទិត+មន ] មានចិត្តរីករាយហើយ, -ត្រេកអរហើយ; វិ.

Websites: WatKhemaraRatanaram.org or WatKhmers.org

**មុទិតោ មនោ យស្ស សោ> មុទិតមនោ** ។

**មុទុ, មុទុក** គុ. [ មុទ+ឧ ] ទន់, ទន់ល្វន់, ទន់ភ្លន់ ។ . **ចិត្តតា** ឥ. ភាវៈនៃ...ជាអ្នកមានចិត្តទន់ ។ . **ជាតិក** គុ. អ្នកមានជាតិដ៏ទន់ ។ . **តាយ** ព្រោះភាវៈនៃ...ជា...ទន់ ។ . **ហទយ** គុ. អ្នកមានហឫទ័យដ៏ទន់ ។

**មុទ្ទិកា** ឥ. [ មុទ+ណ្វុ, ចុះអា_ឥ. ] ចិញ្ចៀន, ចិញ្ចៀនមានត្បូង (វិ. **មោទន្តិ ឯតាយាតិ> មុទ្ទិកា**) ។ នបុំ. ប្រែថា កូនសោ ។

**មុទ្ធា** ឥ. [ មុទ+ធ,ចុះអា_ឥ. ] ក្បាល, អំបែងក្បាល, កំពូល, ប្រាជ្ញាឈ្មោះមុទ្ធា (វិ. **មោទន្តិ ឯត្ថ ឧភាទយោតិ> មុទ្ធា**) ។

**មុនាតិ** កិ. [ មុ+នា+តិ_វ. ឬមុន+អ+តិ_វ. ] ចង, ដឹង ។

**មុនិ** បុំ. [ មុន+ឥ ] អ្នកដឹងនូវធម៌ទាំងពួង (អ្នកប្រាជ្ញ) ; វិ. **សព្វធម្មេ មុនតិ ជានាតីតិ> មុនិ** ។

**មុយ្ហន្តិ** កិ. [ មុហ+យ+អន្តិ_វ. ] វង្វេង, ងងឹត, ភាន់ភាំង, ស្រវាំង ។

**មុសល** បុំ. [ មុស+អល ] អង្រែ (វិ. **មុសតិ ឯតេនាតិ> មុសលោ**) ។ . **សាលា** ឥ. រោងនៃអង្រែ, រោងជាទីទុកនូវអង្រែ ។

**មុសា** និ. ពាក្យកុហក, ពាក្យមិនពិត ។ . **កថា** ឥ. វាចាជាហេតុពោលនូវពាក្យកុហក ។ . **វាទ** បុំ. កិ.ពោលនូវពាក្យកុហក ។

**មុសាវាទី** បុំ. [ មុសា+វទ+ណី ] អ្នកពោលនូវពាក្យកុហក ឬអ្នកមានកិ. ពោលនូវពាក្យកុហកជាប្រក្រតី; វិ. **មុសា វទតីតិ> មុសាវាទី, មុសា វទិតុំ សីលមស្សាតិ វា> មុសាវាទី** ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# មុ-មូ

**មុហុត្ត** ន. [ ហុច្ច+ត, ចុះមុ-អា., លុបច្ច ] មួយរំពេច, មួយស្របក់, មួយភ្លែត ។ - **មត្ត** គុ. កាលត្រឹមតែមួយរំពេច, ... ។ - **សទិស** គុ. ប្រាកដស្មើដោយកាលមួយរំពេច ។

**មុឡ្ហ** ឬ **មូឡ្ហ** គុ. [ មុហ+ឡ្ហត ] វង្វេង, វង្វេងហើយ ។ - **គព្ភ** គុ. មានគភ៌វង្វេងហើយ ។ - **រូប** គុ. មានសភាពវង្វេងហើយ, មានរូបនៃបុគ្គលវង្វេងហើយ ។

**មូគ** គុ. [ មិគ+អ, ឥនៃមិ>ឧ, ឧ>ឩ, ឬមុហ+គ, មុហ>មូ ] គ, មនុស្សគ; វិ. **ចក្ខុមសក្កុណោយុត្តា មិគសជិសោតិ> មូគោ** ។ **មុយ្ហតិតិ ខា> មូគោ** ។

**មូល** នបុំ. [ មូល+អ ] ទីតម្កល់, ទីតាំង, ប្រទេសជាទីតាំង, ខាងដើម, ទីជិត, គល់, ឫស, តម្លៃ, ទ្រព្យជាដើមទុន, មើម ។ - **កម្មដ្ឋាន** នបុំ. កម្មដ្ឋានជាទីតាំង, កម្មដ្ឋានជាខាងដើម។ - **កម្មដ្ឋានមនសិការ** បុំ. កិ.ធ្វើទុកក្នុងចិត្តនូវមូលកម្មដ្ឋាន ។ - **គន្ធ** បុំ. ក្លិននៃឫស ។ - **ឃច្ច** គុ. មានឫសសម្លាប់បង់ហើយ, ឱ្យជាទោសគឺខ្លួនកម្ចាត់បង់ហើយព្រមទាំងឫស, ឱ្យជាធម្មជាតមានឫសគឺ...សម្លាប់បង់ហើយ, មានឫសដកឡើងហើយ ។ - **ឃាត** គុ. មានឫសគឺ...សម្លាប់បង់ហើយ ។ - **ភាវ** បុំ. ភាវៈនៃ...ជាហេតុជាទីតាំង ។

**មូលគណ្ឌ** បុំ. មើមនៃដំឡូង, មើមនៃត្រាវ ។

**មូលគមុដ្ឋិ** ឥ. [ មូលក+មុដ្ឋិ ] ក្តាប់នៃដំឡូង, ក្តាប់នៃមើមដំឡូង, -នៃ

Websites: WatKhemaraRatanaram.org or WatKhmers.org

ត្រាវ ។

**មូសិក** បុ. [ មុស+ណ្ហុ ឬណិក ] កណ្ដុរ ឬកណ្ដោរ (បា. **មុសតិ ថេនេតីតិ> មូសិកោ**) ។ . **បោតក** បុ. កូននៃកណ្ដុរ ។

**មេឃ** បុ. [ មិហ+ឃ ] មេឃ, ភ្លៀង (បា. **មេហតិ សិញ្ចតិ លោកំ វស្សធារាហីតិ> មេឃោ**) ។ . **ឧតុ** នបុ. រដូវនៃមេឃ ។

**មេឃត្ថនិត** គុ. [ មេឃ+ថនិត ] សម្លេងនៃមេឃ, កិ.គ្រហឹមនៃមេឃ, គឺមេឃគ្រហឹមហើយ, -កម្ពុរហើយ ។

**មេត្តចិត្ត** នបុ. [ មេត្តា+ចិត្ត ] ចិត្តក្របដោយមេត្តា, ចិត្តមានមេត្តា ។

**មេត្តា** ឥ. [ មិទ+ត, ចុះអា-ឥ. ] ធម្មជាតិតែងស្រឡាញ់, -រាប់រក, -រាប់អាន ។ . **កម្មដ្ឋាន** នបុ. កម្មដ្ឋានមានមេត្តាជាអារម្មណ៍, កម្មដ្ឋានគឺបណ្ឌិតកំណត់ហើយដោយមេត្តា ។ . **ភាវនា** ឥ. កិ.ញ៉ាំងមេត្តាឱ្យចម្រើន, បញ្ញាជាគ្រឿងញ៉ាំងមេត្តាឱ្យចម្រើន ។ . **វិហារី** បុ. អ្នកមានកិ.នៅដោយមេត្តាជាប្រក្រតី ។ . **សហគត** គុ. ប្រព្រឹត្តទៅដោយមេត្តា, ទៅមួយអន្លើដោយមេត្តា ។

**មេធគ** គុ. [ មេធ+គម+ក្វិ ] សេចក្ដីចង្អៀតចង្អល់ចិត្ត ឬកលហធម៌ជាគ្រឿងដល់នូវកិ.ចម្លាយ (កលហធម៌កម្ចាត់នូវនិស្ស័យនៃខ្លួននិងបុគ្គលដទៃ; បា. **អត្តនោ និស្សយញ្ច បរញ្ច មេធមានោ គច្ឆតីតិ> មេធគោ**) ។

**មេធាវី** គុ. [ មេធា+វី ] អ្នកមានប្រាជ្ញា; បា. **មេធា យស្ស អត្ថីតិ> មេធាវី** ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**មោក្ខន្តិ** កិ. [ មោក្ខ+អ+អន្តិ.វ. ] រួច, ផុត, របូត, ដោះ ។

**មោក្ខ** ចុំ. [ មុច+អ ] ធម៌ជាទីរួចចាកកិលេសមានរាគៈជាដើម ឬធម៌ជាគ្រឿងរួចចាកកិលេសមានរាគៈជាដើម; វិ. **មុច្ចន្តិ ឯត្ថ ឯតេន វា រាគាទីហីតិ> មោក្ខោ** ។ កិ.រួច វិ. **មុច្ចនំ> មោក្ខោ** ។ - **ធម្ម** ចុំ. ធម៌ជាគ្រឿងរួច, ធម៌ជាគ្រឿងញុំាងសត្វឱ្យរួចចាកទុក្ខ ។ - **ធម្មទេសក** គុ. អ្នកសម្ដែងនូវមោក្ខធម៌ វិ. **មោក្ខធម្មំ ទេសេតីតិ> មោក្ខធម្មទេសកោ** ។

**មោគ្គល្លាន** អ.ន. [ មោគ្គល្លី+ណាន ] ជនជាកូននៃព្រាហ្មណីឈ្មោះមោគ្គល្លី (នាមរបស់អគ្គសាវ័កទីពីរគឺព្រះថេរៈឈ្មោះមោគ្គល្លាន) វិ. **មោគ្គល្លិយា អបច្ចំ> មោគ្គល្លានោ** ។

**មោឃ** គុ. [ មុហ+អ, ហ>ឃ ] ឥតប្រយោជន៍, ទទេ, សូន្យ, មោឃៈ ។ - **បុរិស** ចុំ. បុរសមោឃៈ, បុរសទទេ ។

**មោចនវេលា** ឥ. [ មោចន+វេលា ] វេលាជាទីរួច, -ជាទីដោះ, -ជាទីស្រាយ, -ជាទីអាន, ... ។

**មោចយិស្សុ** កិ. [ មុច+ណាយ+ឥំ.អជ្ជ. ] រួចហើយ, ឱ្យរួចហើយ ។

**មោចិត** គុ. [ មុច+ឥ.អា.+ត ] គឺ...ដោះហើយ, -ស្រាយហើយ, ... ។

**មោចេត្វា** អ. [ មុច+ណេ+ត្វា ] ស្រាយហើយ, ដោះហើយ, អានហើយ, ... ។

**មោចេស្សាមិ** កិ. [ មុច+ណេ+ស្សាមិ.ភ. ] នឹងដោះ, នឹងអាន,... ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# មោ

**មោទតិ** កិ. [ មុទ ឬ មោទ+អ+តិ.វ. ] រមែងរីករាយ, ត្រេកអរ ។

**មោទនដ្ឋាន** នថុំ. [ មោទន+ឋាន ] ទីជាទីត្រេកអរ, ទីជាទីរីករាយ ។

**មោនបថ** ថុំ. [ មោន+បថ ] ធម៌ជាផ្លូវនេះនៃមុនី, គន្លងនៃមុនី; គន្លងនៃបុគ្គលអ្នកស្ងៀម ។

**មោនភាវ** ថុំ. [ មោន+ភាវ ] ភាវៈនៃ...ជាមុនី, ភាវៈនៃ...ជាអ្នកស្ងៀម ។

**មោនមត្ត** គុ. [ មោន+មត្ត ] គ្រាន់តែកិ.ស្ងៀម, គ្រាន់តែជាអំពើនៃមុនី, -នៃអ្នកស្ងៀម (មោន៑<មុនិ+ណ = វិ. **មុនិនោ ភាវំ**> **មោ-នំ**) ។

**មោនេយ្យប្បដិបទា** ឥ. [ មោនេយ្យ+បដិបទា ] សេចក្ដីប្រតិបត្តិជាប្រយោជន៍ដល់មុនី, -នៃមុនី ។

**មោរ** ថុំ. [ មុរ+ណ ] ក្ងោក ។ - **កលាបសទិស** គុ. ប្រាកដស្មើដោយសំណុំកន្ទុយនៃក្ងោក ។

**មោហ** ថុំ. [ មុហ+ណ ] សេចក្ដីវង្វេង, កិ.វង្វេង; វិ. **មុយ្ហនំ**> **មោ-ហោ** ។ - **ទោស** គុ. មានមោហៈជាគ្រឿងប្រទូស្ត ។ - **សម្ព-ន្ធន** គុ. មានមោហៈជាគ្រឿងចងព្រម ។ - **សម** គុ. ស្មើដោយមោហៈ ។

**មោហេស្សាមិ** កិ. [ មុហ+ណេ+ស្សាមិ.ភ. ] នឹងញ៉ាំង...ឱ្យវង្វេង, -ឱ្យងេងងោង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**យ** ស.ន. ណា, ឯណា ។

**យក្ខ** ពុំ. [ យក្ខ+អ. ] បុគ្គលដែលគេតែងបូជា (យក្ស, ទេវតា); វិ. **យក្ខិយតេ បូជិយតេតិ> យក្ខោ** ។ . **គហអជគរគហកុម្ភីលគហាទិ** គុ. មានកិ.ចាប់នៃយក្ស និងកិ.ចាប់នៃថ្លាន់ និងកិ.ចាប់នៃក្រពើជាដើម ។ . **នាគសុបណ្ណ** ពុំ. យក្សនិងនាគ និងគ្រុឌ ។

**យក្ខិនី** ឥ. [ យក្ខ+ឥនី ] យក្ខិនី, នាងយក្ខិនី (យក្សស្រី) ។

**យជន្តិ** កិ. [ យជ+អ+អន្តិ.វ. ] បូជា, រមែងបូជា ។

**យជិត្វា** អ. [ យជ+ឥ.អា.+ត្វា ] បូជាហើយ ។

**យញ្ញ** ពុំ. [ យជ+ញ, ជ>ញ ] កិ.បូជា, យញ្ញៈ; វិ. **យជនំ> យញ្ញោ** ។ មួយយ៉ាងទៀត វិធីជាគ្រឿងបូជា; វិ. **យជន្តិ អនេនាតិ> យញ្ញោ** ។ . **សុត្តក** នពុំ. អំបោះឬខ្សែអំបោះដើម្បីយញ្ញ ៈ ។ . **អត្ថាយ** ដើម្បីប្រយោជន៍ដល់យញ្ញៈ ។

**យដ្ឋិ** ឥ. [ យត+តិ, តនៃយត>ដ, តនៃតិ>ឋ ] ឈើច្រត់, ដង ។ . **កោដិ** ឥ. ចុងនៃឈើច្រត់ ។ . **កោដិគ្គហណកិច្ច** នពុំ. កិច្ចដោយកិ. កាន់នូវចុងនៃឈើច្រត់ ។

**យត្តកោ, -កា, -កំ** គុ. មានប្រមាណត្រឹមណា, -ប៉ុនណា; មានមាន ប្រមាណឯណា ។

**យតោ** អ.ស.ន. [ យ+តោ ] អំពី...ណា, ក្នុង...ណា ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**យត្រ** អ.ស.ន. [ យ+ត្រ ] ក្នុង...ណា, ត្រង់...ណា ។

**យត្ថកាម** គុ. [ យត្ថ+កាម ] មានសេចក្តីប្រាថ្នាក្នុងអារម្មណ៍ណា ។ . **និបាតិនំ** មានកិ.ធ្លាក់ចុះក្នុងកាមណានីមួយ, មានកិ.ធ្លាក់ចុះតាមតែប្រទះក្នុងកាម, មានកិ.ធ្លាក់ចុះដោយមិនសល់ក្នុងសេចក្តីប្រាថ្នាក្នុងអារម្មណ៍ណាមួយ ។

**យន្តនាឡិក** នបុំ. [ យន្ត+នាឡិក ] ចំពួយនៃយន្ត, ... ។

**យន្តិ** កិ. [ យា+អ+អន្តិ.វ. ] ទៅ, ដល់ ។

**យថា** និ. [ យ+ថា ] ប្រការៈណា, ដោយប្រការៈណា, យ៉ាងណា ។ល។ . **អជ្ឈាសយំ** តាមអធ្យាស្រ័យ, គួរតាមអធ្យាស្រ័យ, គួរដល់អធ្យាស្រ័យ ។ . **ចិន្តិត** គុ. ដែលខ្លួនគិតហើយយ៉ាងណា, តាមដែលខ្លួនគិតហើយ ។ . **ឋាន** នបុំ. ទីយ៉ាងណា, ទីដូចដែល, ទីដដែល ។ . **ឋិតា** គុ. ឈរនៅហើយយ៉ាងណា, ឈរនៅដដែល . **តំ** និ. ដោយប្រការណា, ដោយពិត ។ . **ធោត** គុ. ដែលខ្លួនលាងហើយយ៉ាងណា, ដូចជាគឺគេលាងហើយ ។ . **និក្ខិត្ត** គុ. ដែលខ្លួនទុកហើយយ៉ាងណា, ដែលខ្លួនកប់ទុកហើយយ៉ាងណា ។ . **និសិន្ន** អង្គុយហើយយ៉ាងណា, អង្គុយដូចដែល ។ . **នុសិដ្ឋ** គុ. ដែល...ប្រៀនប្រដៅហើយយ៉ាងណា, តាមឱវាទដែល...ប្រៀនប្រដៅហើយ ។ . **បសាទនំ** គុ. តាមសេចក្តីជ្រះថ្លា ។ . **បត្ថិតំ** គុ. ដែលខ្លួនប្រាថ្នាហើយយ៉ាងណា, តាមដែលខ្លួនប្រាថ្នាហើយ ។ . **បូរិតំ** គុ. ពេញហើយយ៉ាងណា ។ . **ផាសុកដ្ឋាន** ទីមាន

Websites: WatKhemaraRatanaram.org or WatKhmers.org

សេចក្ដីសប្បាយយ៉ាងណា, ទីគួរតាមសេចក្ដីសប្បាយ, ទីគួរតាមសេចក្ដីស្រួល ។ - **ពលំ** កិ.វិ. តាមកម្លាំង, គួរតាមកម្លាំង, តាមគួរដល់កម្លាំង ។ - **ភិរន្តំ** តាមសេចក្ដីរីករាយ, តាមគួរដល់អធ្យាស្រ័យ ។ - **ភូតំ** តាមសេចក្ដីពិត ។ - **មន** គួរតាមចិត្ត ។ - **រុចិ** តាមសេចក្ដីគាប់ចិត្ត ។ - **រុចិតំ** ដែលខ្លួនគាប់ចិត្តហើយយ៉ាងណា, តាមដែលខ្លួនគាប់ចិត្ត ។ - **លទ្ធំ** ដែលខ្លួនបានហើយយ៉ាងណា, តាមដែលខ្លួនបានហើយ ។ - **វេគំ** តាមកម្លាំង, តាមសន្ទុះ, តាមល្បឿន ។ - **សភាវតោ** តាមសភាពដ៏គួរសម, គួរតាមសេចក្ដីពិត ។ - **សន្និហិតំ** ដែលខ្លួនចាត់ចែងហើយយ៉ាងណា ។ - **សទ្ធំ** តាមសទ្ធា ។ - **សុខំ** តាមសេចក្ដីសុខ, តាមស្រួល ។ - **សុតំ** ដែលខ្លួន ឮហើយយ៉ាងណា, តាមដែលខ្លួនឮហើយ ។

**យថិច្ឆិកំ** គុ. [ យថា+ឥច្ឆិកំ ] តាមសេចក្ដីប្រាថ្នា ។

**យថិច្ឆិតំ** គុ. [ យថា+ឥច្ឆិតំ ] ដែលខ្លួនប្រាថ្នាហើយយ៉ាងណា, តាមសេចក្ដីប្រាថ្នា ។

**យទា** និ. [ យ+ទា ] ក្នុងកាលណា, កាលណា ។

**យទិ** និ. បើ, ថាបើ ។

**យន្នូន** និ. បើដូច្នោះ, បើដូច្នោះមានតែ, ដូចម្ដេចហ្ន,.... ។

**យមកវគ្គវណ្ណនា** ឥ. [ .+វណ្ណ+យុ+អា_ឥ. ] កថាជាគ្រឿងពណ៌នានូវសេចក្ដីនៃយមកវគ្គ; វិ. **យមកវគ្គស្ស អត្ថំ វណ្ណេតិ ឯតាយាតិ> យមកវគ្គវណ្ណនា** ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**យមក** គុ. [ យម+ណ្ក ] ជាគូគ្នា, របស់ជាគូគ្នា ។

**យមកបាដិហារិយ** នថុំ. [ .+បាដិហារិយ ] បាដិហារ្យមានភ្លើងនិងទឹកជាគូគ្នា, យមកបាដិហារ្យ ។ . **សមាគម** ចុំ. សមាគមនិម្មិតយមកបាដិហារ្យ, កិ.ជួបជុំនៃ... ។

**យមកបាដិហិរ** នថុំ. (ដូចយមកបាដិហារិយ) ។

**យមទូត** ចុំ. [ .+ទូត ] ទូតនៃស្តេចយមៈ, ទូតនៃយមរាជ, បម្រើនៃ... ។

**យមាមសេ** កិ. [ យម+អ+ស្យាម.ភ. ចូម.វ. ] នឹងវិនាស, នឹងលំបាក, ត្រដាបត្រដួស ។

**យស** ចុំ. [ យជ+អ, ជ>ស ] យស (វិ. **យជតិ ឯតេនាតិ> យសោ ។ សព្វត្ថ យាតីតិ វា> យសោ**) ។ . **សម្បត្តិ** ឥ. កិ.ដល់ព្រមនៃយស, .ដោយយស ។

**យសស្សី** គុ. [ យស+សី ] អ្នកមានយស; វិ. **យសោ យស្ស អត្ថីតិ> យសស្សី** ។

**យាគុ** ឥ. [ យា+គុ ] បបរ, យាគូ (វិ. **យាតីតិ> យាគុ**) ។ . **ខជ្ជក** នថុំ. បបរនិងបង្អែម (ខជ្ជក<ខាទ+ត, ចុះ កសកត្ត = វត្ថុពីបុគ្គលគប្បីទំពាស៊ី) ។ . **តណ្ឌុល** នថុំ. អង្ករដើម្បីបបរ ។ . **ភត្តបូវ** ចុំ. បបរនិងបាយនិងនំ ។ . **ភត្តខាទនីយតម្ពូល-គន្ធមាលាបិលន្ធន** នថុំ. បបរនិងបាយនិងបង្អែមនិងម្លូនិងគ្រឿងក្រអូបនិងកម្រងផ្កានិងគ្រឿងប្រដាប់ ។

**យាចក** ចុំ. [ យាច+ណ្ក ] អ្នកសូម, ស្មូម; វិ. **យាចតីតិ> យាចកោ** ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**យាចតិ** កិ. [ យាច+អ+តិ.វ. ] សូម, អង្វរ ។

**យាចនា** ឥ. [ យាច+យុ+អា.ឥ. ] កិ. សូម, កិ. អង្វរ ។

**យាចយោគ** បុំ. [ យាច+យោគ ] អ្នកគួរដល់កិ.សូម, អ្នកគួរដល់សូម (**យោគ**<យុជ+ណ, ជ>គ = វិ. **យុជ្ជតីតិ**> **យោគោ**) ។

**យាតិ** កិ. [ យា+អ+តិ.វ. ] ទៅ, ដល់ ។

**យាថ** កិ. [ យា+អ+ថ.ប ] ចូរទៅ, ចូរដល់ ។

**យាទិស** គុ. [ យ+ទិស+ក្វិ ] ប្រាកដដូចជាឯណា, ដូចណា, បែបណា; វិ. **យោ វិយ ទិស្សតីតិ**> **យាទិសោ** ។

**យាន** នបុំ. [ យា+យុ ] វាហនៈជាគ្រឿងទៅ (យាន); វិ. **យាតិ ឯតេនាតិ**> **យានំ** ។

**យានក** នបុំ. [ យា+យុ+ក.សកត្ថ ] យានឬយានតូច (ក.បច្ច័យ ឬ ក.សកត្ថនេះកាលបើចុះមកភ្ជាប់នៅចុងនាមស័ព្ទណា នាមស័ព្ទនោះត្រូវប្រែថាតូច ដូច **បុត្តក** កូនតូច, **មញ្ចក** គ្រែតូច មានប៉ុណ្ណោះជាដើម) ។ . **អន្តរ** នបុំ. ចន្លោះនៃយានតូច ។

**យានានុឃាត** នបុំ. ឬ គុ. [ យាន+អនុឃាត ] កិ. បៀតបៀនរឿយៗនៃយាន, កិ. ទង្គិចរឿយៗនៃយាន, កិ.ប៉ះទង្គិចរឿយៗនៃយាន ។

**យាបនមត្ត** គុ. [ យាបន+មត្ត ] អាហារគ្រាន់តែជាគ្រឿងញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅ, អាហារត្រឹមតែមួយឆ្អែត (**យាបន**<យប+យុ = វិ. **យាបេតិ ឯតេនាតិ**> **យាបនំ**) ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**យាបនីយ** កិ. ឬ គុ. [ យប+អនីយ ] គឺ...គប្បីឱ្យប្រព្រឹត្តទៅ, -គប្បីញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅ ។

**យាបយិស្សុ** កិ. [ យប+ណយ+ឧំ-អជ្ជ. ] ញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅហើយ ។

**យាបេតិ** កិ. [ យប+ណេ+តិ-វ. ] ញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅ ។

**យាម** ពុំ. [ យា+ម ] យាម, វ័យ, វេលា (វិ. **យាតិ គច្ឆតីតិ> យា. មោ**) ។

**យាវ** និ. ត្រឹមណា, ដរាបណា ។

**យាវតីវ** និ. កាលមានប្រមាណឯណា, មានកំណត់ត្រឹមណា, មានប្រមាណត្រឹមណា ។

**យាវជរា** [ យាវ+ជរា ] ដរាបដល់ជរា, ដរាបដល់ចាស់ ។

**យាវជ្ជកាលា** [ យាវ+អជ្ជ+កាល ] ដរាបអំពីកាលក្នុងថ្ងៃនេះ ។

**យាវជ្ជតនា** [ យាវ+អជ្ជ+តន ] ដរាបអំពីកាលមានក្នុងថ្ងៃនេះ ។

**យាវជីវ** កំណត់ត្រឹមណានៃជីវិត, កំណត់មានប្រមាណឯណានៃជីវិត; វិ. **ជីវស្ស យត្តកោ បរិច្ឆេទោ> យាវជីវំ** ។

**យាវតតិយំ** ដរាបដល់គ្រាទី៣, កំណត់អស់វារៈជាគម្រប់៣ ។

**យាវតាយុក** [ យាវតា+អាយុ+ក ] កាលមានប្រមាណឯណានៃអាយុ, អស់កំណត់នៃអាយុ ។

**យាវតិក** [ យាវតា+ណិក ] មានប្រមាណត្រឹមណា, មានកំណត់ត្រឹមណា ។

**យាវទត្ថ** [ យាវ+អត្ថ, ចុះទ_អា. ] ប្រយោជន៍ប៉ុន្មាន, ដរាបដល់សេក្ដីត្រូវការ, មានប្រយោជន៍ត្រឹមណា (ដរាបដល់ឆ្អែត) ។

**យាវមហន្ត** [ យាវ+មហន្ត ] មានទំហំត្រឹមណា, មានទំហំប៉ុនណា ។

**យាសិ** កិ. [ យា+អ+សិ_វ. ] ទៅ, ដល់ ។

**យាហិ** កិ. [ យា+អ ហិ_ច ] ចូរទៅ, ចូរដល់ ។

**យិដ្ឋ** គុ. [ យជ+ត ] គឺ...បូជាហើយ ។ **- យាគ** ចុំ. យញ្ញៈដែលបុគ្គលបូជាហើយ, ការបូជាដែលបុគ្គលបូជាហើយ ។

**យុគ** នចុំ. [ យុជ+អ ] គូ, នឹម ។ **- គ្គាហ** កិ. វិ. កាន់យកនូវគូ, កាន់យកជាគូ ។ **- នង្គលាទិ** គុ. មាននឹមនិងនង្គ័លជាដើម ។ **- នង្គលត្ថ** ចុំ. ប្រយោជន៍ដល់នឹមនិងនង្គ័ល ។

**យុជ្ជតិ** កិ. [ យុជ+យ+តិ_វ. ] គួរ, ប្រកប ។

**យុជ្ឈតិ** កិ. [ យុធ+យ+តិ_វ. ] ច្បាំង, ជល់ ។

**យុជ្ឈិតុកាម** គុ. [ យុជ្ឈិតុំ+កម+ណ ] អ្នកចង់ដើម្បីច្បាំង; វិ. **យុជ្ឈិតុំ កាមេតីតិ> យុជ្ឈិតុកាមោ** ។

**យុញ្ជតិ** កិ. [ យុជ+អ+តិ_វ., ចុះនិ_អា. ] ប្រកប ។

**យុត្ត** គុ. [ យុជ+ត ] គួរ, ប្រកប, គួរហើយ, ប្រកបហើយ ។ **- តរ** គុ. គួរជាង, គួរវិសេស ។ **- រូប** គុ. មានសភាពគួរ, ដ៏គួរ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

. **បយុត្ត** គុ. ប្រកបហើយខ្វល់ខ្វាយហើយ, អ្នកប្រកបហើយទាំងប្រកបទូរទៅហើយ ។

**យុទ្ធ** ន. ឬ កិ. [ យុធ+ត ] កិ.ច្បាំង, គឺ...ច្បាំងហើយ ។ . **សជ្ជ** គុ. អ្នកមានកិ.រៀបចំដើម្បីកិ.ច្បាំង, អ្នកត្រៀមដើម្បីកិ.ច្បាំង ។

**យុវ** ពុំ. [ យុ+អ, ឧនៃយុ>ឧវ ] កម្លោះ, ប្រុសកម្លោះ, ក្មេង, ជំទង់ ។

**យុវតី** ឥ. [ យុ+តិ, ចុះញ ] ក្រមុំ, ស្រីក្រមុំ, ជំទង់ ។

**យូថ** ពុំ. [ យុ+ថ ] ហ្វូង, មេខ្លោង ។ . **បតិ** ពុំ. ម្ចាស់នៃហ្វូង ។

**យេភុយ្យេន** និ. [ យេភុយ្យ+នា ] ដោយច្រើន, ច្រើនតែ ។

**យោគ** ពុំ. [ យុជ+ណ ] ព្យាយាមជាគ្រឿងប្រកប, សេចក្តីព្យាយាម; វិ. **យុញ្ជតិ ឯតេនាតិ> យោគោ** ។ កិ.ប្រកប; វិ. **យុជនំ> យោគោ** ។ ព្យាយាមគឺបុគ្គលគប្បីប្រកប; វិ. **យុញ្ជិតព្វោតិ> យោគោ** ។

**យោគាវចរ** ពុំ. [ យោគ+អវ+ចរ+អ ] អ្នកព្រាច់ចុះកាន់សេចក្តីព្យាយាម (ព្រះយោគាវចរ); វិ. **យោគំ ចរិយំ អវចរតិ គវេតីតិ> យោគាវចរោ** ។

**យោជន** នពុំ. [ យុជ+យុ ] កិ.ប្រកប, គ្រឿងប្រកប (យោជន៍ជាមាត្រាវាស់បូរាណដែលមាននិយាយក្នុងគម្ពីរបាលីចែកជាពីរគឺ ១. សម្រាប់វាស់ប្រវែងភូមិភាគ ឬចម្ងាយផ្លូវចំនួន៤គាវុតគឺ ៤០០សិនជាមួយយោជន៍, ២. សម្រាប់វាស់កំពស់ដូចកំពស់ភ្នំ ឬដើមឈើកំណត់ត្រឹម៧ហត្ថជាមួយយោជន៍) ។ . **សត** ប.សំ. រយនៃ

Websites: WatKhemaraRatanaram.org or WatKhmers.org

យោជន៍ ។ - **មត្ត** គុ. មានយោជន៍ជាប្រមាណ, ត្រឹមតែមួយយោជន៍ ។ - **សមុព្វេធ** គុ. ឬ ន. មានរយៈនៃយោជន៍ជាចំណែកខ្ពស់, មានកំពស់អស់រយៈនៃយោជន៍ ។ - **សតិក** គុ. ប្រកបដោយរយៈនៃយោជន៍ ។ - **អព្ភន្តរ** គុ. ខាងក្នុងនៃយោជន៍ ។

**យោជនិក** គុ. [ យោជន+ណិក ] ប្រកបដោយយោជន៍ ។

**យោជយិំសុ** កិ. [ យុជ+ណយ+ឥំ.អជ្ជ. ] ប្រកបហើយ ។

**យោជាបេត្វា** អ. [ យុជ+ណាបេ+ត្វា ] ឱ្យប្រកបហើយ, ញុំាង...ឱ្យប្រកបហើយ ។

**យោជេតិ** កិ. [ យុជ+ណេ+តិ.វ. ] ប្រកប, ឱ្យប្រកប ។

**យោត្ត** នបុំ. [ យុជ+ត ] វត្ថុជាគ្រឿងប្រកប (ខ្សែ); វិ. **យោជន្តិ អនេនាតិ> យោត្តំ** ។ - **កោដិ** ឥ. ចុងនៃខ្សែ ។

**យោធ** បុំ. [ យុធ+ណ ] អ្នកច្បាំង (យោធា, ទាហាន); វិ. **យុជ្ឈតីតិ> យោធោ** ។

**យោនិជ** គុ. [ យោនិ+ជាត ] អ្នកកើតហើយអំពីកំណើត, -អំពីយោនី; វិ. **យោនិតោ ជាតោតិ> យោនិជោ** ។

**យោនិមុខ** នបុំ. [ យោនិ+មុខ ] មាត់នៃយោនី; -នៃកំណើត ។

**យោនិសោ** អ. ដោយឧបាយ, ដោយគន្លង, ដោយប្រាជ្ញា ។ - **មនសិការ** បុំ. កិ.ធ្វើទុកក្នុងចិត្តដោយឧបាយ, កិ.ធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# រ

រក្ខ កិ. [ រក្ខ+អ+ហិ.ប., លុបហិ.ប. ] ចូររក្សា ។

រក្ខតិ កិ. [ រក្ខ+អ+តិ.វ. ] រក្សា, រមែងរក្សា ។

រក្ខន្តិ កិ. [ រក្ខ+អ+អន្តិ.វ. ] រក្សា, រមែងរក្សា ។

រក្ខាមិ កិ. [ រក្ខ+អ+មិ.វ. ] រក្សា, រមែងរក្សា ។

រក្ខាហិ កិ. [ រក្ខ+អ+ហិ.ប. ] ចូររក្សា ។

រក្ខិស្សតិ កិ. [ រក្ខ+អ+ឥ.អា.+ស្សតិ.ភ. ] នឹងរក្សា ។

រក្ខេយ្យ កិ. [ រក្ខ+អ+ឯយ្យ.ស. ] គប្បីរក្សា ។

រក្ខិយមាន គុ. [ រក្ខ+ឥ.អា.+យ+មាន ] គឺ...កាលរក្សា, គឺ...កំពុងរក្សា ។

រក្ខិត គុ. [ រក្ខ+ឥ.អា.+ត ] រក្សាហើយ, គឺ...រក្សាហើយ ។ - វន-សណ្ឌ ចុំ. ដងនៃព្រៃគឺ...រក្សាហើយ, ដងនៃព្រៃឈ្មោះ... ។

រក្ខិត្វា អ. [ រក្ខ+ឥ.អា.+ត្វា ] រក្សាហើយ ។

រក្ខិតព្វ កិ. [ រក្ខ+ឥ.អា.+តព្វ ] គឺ...គប្បីរក្សា ។ - យុត្តក គុ. គួរគឺ...គប្បីរក្សា ។

រក្ខា ឥ. [ រក្ខ+អ+អា.ឥ. ] កិ.រក្សា ។

រក្ខណ, រក្ខន នចុំ. [ រក្ខ+យុ ] កិ.រក្សា; វិ. រក្ខិយតេតិ> រក្ខណំ ។ - កិច្ច នចុំ. កិច្ចគឺកិ.រក្សា ។ - សទិស គុ. ប្រាកដស្មើដោយកិ.រក្សា ។

រក្ខសបរិគ្គហិត គុ. [ រក្ខស+បរិគ្គហិត ] គឺអារក្សទឹកហួងហែងហើយ,

Websites: WatKhemaraRatanaram.org or WatKhmers.org

គឺខ្មោចទីករក្សាហើយ ។ រក្ខសិ<រក្ខ+ស = យក្សជាដែនរក្សានូវខ្លួន; វិ. រក្ខតិ អត្តានំ ឯតស្មាតិ> រក្ខសោ ។ ឥ. រក្ខសី ចុះឦបច្ច័យ ។

**រង្គមជ្ឈ** នបុំ. [ រង្គ+មជ្ឈ ] កណ្ដាលនៃរោង, -នៃរោងរាំ; កណ្ដាលនៃប្រទេសជាទីរីករាយ (រង្គ<រជ+អ, ចុះនិ.អា. = វិ. រញ្ជតិ ឯត្ថាតិ> រង្គោ ។

**រជ** បុំ. ធូលី (វិ. រតិយា ជាយតីតិ> រជោ) ។ លុប តិ ។

**រជ្ជ** នបុំ. [ រាជ+ណ្យ ] ភាវៈនៃខ្លួនជាស្ដេច (រាជ្យ); វិ. រញ្ញោ (អត្តនោ) ភាវោ> រជ្ជំ ។

**រជ្ជន្តុ** កិ. [ រជ+យ+អន្តុ-ប. ] ចូរជ្រលក់, ចូររីករាយ ។

**រជ្ជមាន** គុ. [ រជ+យ+មាន ] កាលរីករាយ, កាលត្រេកអរ ។

**រជ្ជសិរី** ឥ. [ រជ្ជ+សិរី ] សិរីគឺភាវៈនៃបុគ្គលជាស្ដេច ។ - **ទាយិកា** ឥ. អ្នកឱ្យនូវសិរីគឺភាវៈនៃខ្លួនជាស្ដេច ។ - **សុខ** នបុំ. សុខគឺ... ។

**រជ្ជុ** ឥ. [ រុធ+ជុ, ឧនៃរុ>អ ] ខ្សែ (វិ. រុន្ធតិ ឯតាយាតិ> រជ្ជុ) ។ - **កោដិ** ឥ. ចុងឬទីបំផុតនៃខ្សែ ។ - **គាហ** បុំ. អ្នកកាន់នូវខ្សែ (នាយសារថី) ។ - **វដ្ដិ** ឥ. ខ្នាញ់នៃខ្សែ ។

**រជត** នបុំ. [ រញ្ជ+ត ] វត្ថុជាទីរីករាយ (ប្រាក់); វិ. រញ្ជន្តិ ឯត្ថាតិ> រជតំ ។ - **ខចិត** គុ. វិចិត្រដោយប្រាក់ ។ - **បដ្ដបរិក្ខិត្ត** គុ. គឺផ្ទាំងនៃប្រាក់បិទបាំងហើយ, គឺដំបារនៃប្រាក់ព័ទ្ធព័ទ្ធហើយ ។ - **បូរ** គុ. ពេញដោយប្រាក់ ។ - **មុត្តាបវាឡវេឡិរាទិ** គុ. (រតនៈ) មាន

Websites: WatKhemaraRatanaram.org or WatKhmers.org

ប្រាក់និងកែវមុក្តា និងកែវប្រពាឡ និងពេជ្រជាដើម ។ - **វដំសកា** ឥ. សង្វារជាវិការៈនៃប្រាក់ ។ - **សោបាណ** បុំ. ជណ្តើរជាវិការៈនៃប្រាក់ ។ - **សោបាណសីស** នបុំ. ក្បាលនៃជណ្តើរជាវិការៈនៃប្រាក់ ។

**រជន** នបុំ. [ រជ+យុ ] កិ.ជ្រលក់, ទឹកជ្រលក់, ទឹកសម្រាប់ជ្រលក់; វិ. **រជិយតីតិ> រជនំ, រជតិ ឯតេនាតិ> រជនំ** ។

**រជមិស្សក** គុ. [ រជ+មិស្សក ] ដីច្រឡំដោយធូលី, ច្រឡូកច្រឡំដោយធូលី ។

**រជស្សិរ** គុ. [ រជ+សិរ ] មានធូលីពួដីក្បាល; វិ. **រជោ សិរស្មឹ យស្ស សោ> រជស្សិរោ** ។

**រជិត្វា** អ. [ រជ+ឥ_អា.+ត្វា ] ជ្រលក់ហើយ ។

**រជោជល្ល** នបុំ. [ រជ+ជល្ល ] ភាវៈនៃបុគ្គលមានកាយប្រឡាក់ដោយធូលី, កិ.ប្រឡាក់ដោយធូលី ។

**រជោហរណ** នបុំ. [ រជ+ហរណ ] កិ.នាំបង់នូវធូលី, សំពត់សម្រាប់ជូតនូវធូលី ។ - **ចណ្ឌាលកុមារកមេទកថាលិកោបមា** គុ. មានឧបមា (សេចក្តីប្រៀប) ដោយសំពត់សម្រាប់ជូតនូវធូលី និងកុមារនៃមនុស្សចណ្ឌាល និងភាជនៈសម្រាប់ដាក់នូវខ្លាញ់, មានសំពត់សម្រាប់ជូតនូវធូលី និងក្មេងនៃជនចណ្ឌាល និងភាជនៈដាក់នូវខ្លាញ់ជាឧបមា ។

**រញ្ជិយន្តិ** កិ. [ រញ្ជ+ឥ_អា.+យ+អន្តិ_វ. ] រមែងត្រេកអរ, រីករាយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**រដ្ឋ** នប៉ុ. [ រឋ+ត=ប្រែថា" ទៅ" ] ដែន (វិ. **រឋន្តិ ឯត្ថ ឆាគរាណ-យោគិ> រដ្ឋំ** ) ។ - **បិណ្ឌ** ចុំ. ដុំបាយនៃអ្នកដែន, ដុំបាយជារបស់នៃអ្នកដែន ។ - **វាសី** ចុំ. អ្នកនៅក្នុងដែន, អ្នកមានកិ.នៅក្នុងដែនជាប្រក្រតី ។

**រត** គុ. ឬ កិ. [ រម+ត ] ត្រេកអរហើយ, រីករាយហើយ ។

**រត្ត** គុ. [ រញ្ជ+ត ] ក្រហម, ពណ៌ក្រហម ។ - **កម្ពល** ចុំ. សំពត់កម្ពលមានពណ៌ក្រហម ។ - **កម្ពលសទិស** គុ. ប្រាកដស្មើដោយសំពត់កម្ពលមានពណ៌ក្រហម ។ - **កម្ពលសាណិ** ឥ. រនាំង (ភាំងនន) ជាវិការៈនៃសំពត់កម្ពលមានពណ៌ក្រហម ។ - **ចន្ទន** នប៉ុ. ចន្ទន៍ក្រហម ។ - **វណ្ណតាយ** ព្រោះភាវៈនៃជើងជាអវយវៈមានពណ៌ក្រហម ។ - **វត្ថ** នប៉ុ. សំពត់មានពណ៌ក្រហម ។ - **វត្ថនិវត្ថ** គុ. ស្លៀកនូវសំពត់មានពណ៌ក្រហម, ឱ្យជាស្រីស្លៀកនូវ... ។ - **សាខារុក្ខ** ចុំ. ដើមឈើមានមែក ក្រហម ។ - **សុវណ្ណនាវា** ឥ. ទូកជាវិការៈនៃមាសសុទ្ធ, .នៃមាសមានពណ៌ក្រហម ។

**រត្ត** គុ. ឬ កិ. [ រញ្ជ+ត ] ត្រេកអរហើយ, រីករាយហើយ ។

**រតិ** ឥ. [ រម+តិ ] សេចក្ដីត្រេកអរ; វិ. **រមណំ> រតិ** ។

**រត្តិ** ឥ. [ រញ្ជ+តិ ] រាត្រី, យប់ (វិ. **រញ្ជន្តិ ឯត្ថាតិ> រត្តិ**) ។ - **ដ្ឋាន** នប៉ុ. ទីជាទីនៅក្នុងរាត្រី, ទីជាទីនៅក្នុងវេលាយប់ ។ - **ដ្ឋានទិវា-ដ្ឋាន** នប៉ុ. ទីជាទីនៅក្នុងវេលាយប់និងទីជាទីនៅក្នុងវេលាថ្ងៃ ។ - **ភាគ** ចុំ. ចំណែកនៃរាត្រី ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**រត្តិន្ទិវ** ចុំ. [ រត្តិ+ទិវ, ផ្លាស់ទិត្តហិតជា ន>រត្តិន្ទិវ ] យប់និងថ្ងៃ ។ **-បុព្វ-ណ្ហាទិ** គុ. (កាល) មានយប់និងថ្ងៃ និងកាលជាខាងដើមនៃថ្ងៃជាដើម, មានយប់និងថ្ងៃ និងពេលព្រឹកជាដើម ។

**រតន** នចុំ. [ រម+តន, លុប ម ] វត្ថុជាទីត្រេកអរនៃជន (កែវ); វិ. **រមន្តិ ឯត្ថាតិ> រតនំ** ។ (<រតិ+តន+ណ, លុបតិ) ធម្មជាតិផ្សាយនូវសេចក្តីត្រេកអរ; វិ. **រតិំ តនោតីតិ> រតនំ** ។ <តិ+ជន+ណ = ធម្មជាតិញ៉ាំងសេចក្តីត្រេកអរឱ្យកើត; វិ. **រតិំ ជនេតីតិ> រតនំ** ។ **-អគ្ឃិយកាញ្ចនគ្ឃិយសមិស** គុ. ប្រាកដស្មើដោយគ្រឿងបូជាជាវិការៈនៃកែវ និងគ្រឿងបូជាជាវិការៈនៃមាស ។ អគ្ឃិយ<អគ្ឃ+ណ្យ ឬឥយបច្ច័យ = ប្រែថា បូជា, តម្លៃ; វិ. **អគ្ឃនំ បូជនំ> អគ្ឃិយំ** ។ **-មកុល** នចុំ. ផាត្តក្រពុំ, មួយគត់ ។ **-មណ្ឌប** ចុំ. មណ្ឌប (បារាំ) ជាវិការៈនៃកែវ ។ **-រាសិ** ចុំ. គំនរនៃកែវ ។ **-វំស** នចុំ. ភ្លៀងគឺកែវ ។ **-វិមាន** នចុំ. វិមានជាវិការៈនៃកែវ, វិមានគឺបុញ្ញកម្មធ្វើហើយដោយកែវ ។

**រតនមយ** គុ. [ រតន+មយ ] ជាវិការៈនៃកែវ, សម្រេចហើយដោយកែវ ។

**រថ** ចុំ. [ រម+ថ ] រថ, រទេះ (វិ. **រមតេ ភ័ន្សតេ អនេនាតិ> រថោ**) ។ **-ចក្ក** នចុំ. កង់នៃរថ ។ **-ធុរ** នចុំ. ទូកនៃរថ ។ **-បញ្ជរ** ចុំ. ផ្ទះនៃរថ, រាងនៃរថ ។ **-សីស** នចុំ. ក្បាលនៃរថ, ចន្ទោលនៃរថ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# រ

**រន្ធ** នបុំ. [ រមឬរណ+ធ ] រន្ធ, ប្រហោង, ទោស ពិ. **រមន្តិ ឯត្ថ សប្បានយោតិ> រន្ធំ** ។ . **គវេសក** គុ. អ្នកស្វែងរកនូវទោស; វិ. **រន្ធំ គវេសតីតិ> រន្ធគវេសកោ** ។

**រមណីយ** គិ. [ រម+អនីយ, ន>ណ ] គឺបុគ្គលគប្បីត្រេកអរ; វិ. **រមិតព្វន្តិ> រមណីយំ** ។ ប្រើជា **រម្មណីយំ** ក៏មាន ។

**រមន** នបុំ. [ រម+យុ ] សេចក្តីត្រេកអរ, សេចក៏រីករាយ; វិ. **រមិយ-តេតិ> រមនំ** ។

**រមាបេត្វា** អ. [ រម+ណាបេ+ត្វា ] ឱ្យត្រេកអរហើយ,.... ។

**រមិស្សន្តិ** កិ. [ រម+អ+ឥ.អា.+ស្សន្តិ.ភ. ] នឹងត្រេកអរ, នឹងរីករាយ ។

**រវន្ត** គុ. [ រវ+អន្ត ] កាលស្រែក, កំពុងស្រែក, កាលរងាវ ។

**រវិ** កិ. [ រវ+អ+ឦ.អជ្ជ ] ស្រែកហើយ, រងាវហើយ ។

**រវិត្វា** អ. [ រវ+ឥ.អា.+ត្វា ] ស្រែកហើយ, រងាវហើយ ។

**រស** បុំ. [ រស+អ ] (អាហារ) ជាទីត្រេកអរនៃសត្វ (រស); វិ. **រសន្តិ កំ សត្តា អស្សាទេន្តីតិ> រសោ** ។ . **ជាននត្ថំ** ដើម្បីកិ.ដឹងនូវរស ។ . **តណ្ហា** ឥ. តណ្ហាក្នុងរស, តណ្ហាអាស្រ័យនូវរស ។ . **បិណ្ឌបាត** បុំ. បិណ្ឌបាតប្រកបដោយរស ។ . **បិណ្ឌបាត-ទាននិស្សន្ទ** បុំ. វិបាកជាគ្រឿងហូរចេញនៃកិ.ឱ្យនូវបិណ្ឌបាតប្រកបដោយរស, អានិសង្សនៃកិ.ឱ្យនូវ... ។ . **ភោជន** នបុំ. ភោជនប្រកបដោយរស ។ . **លោភ** បុំ. សេចក្តីលោភក្នុងរស,

Websites: WatKhemaraRatanaram.org or WatKhmers.org

សេចក្ដីជាប់ជំពាក់ក្នុងរស ។

**រសោជា** ឥ. [ រស+ឱជា ] ឱជាដែលកើតអំពីរស ។

**រស្មិ** ឥ. [ រស+មិ ] រស្មី, ខ្សែ (ជាគ្រឿងត្រេកអរ, ជាគ្រឿងចង; វិ. **រសន្តិ សត្តា ឯតាយាតិ> រស្មិ**) ។

**រហទ** បុំ. [ រហ+ទ ] អន្លង់, អន្លង់ទឹក ។

**រហស្សកម្ម** នបុំ. [ រហស្ស+កម្ម ] កម្មមានក្នុងទីស្ងាត់, -ទីកំបាំង; អំពើស្ងាត់កំបាំង ។ រហស្សប្រែថា " មានក្នុងទីស្ងាត់ "; វិ. **រហសិ ភវំ ភម្មំ> រហស្សំ** ។

**រហិត** គុ. [ រហ+ឥ.អា.+ត ] ប្រាសហើយ, វៀរហើយ ។

**រហោ** និ. កំបាំង, ស្ងាត់; ក្នុងទីកំបាំង, ក្នុងទីស្ងាត់ ។ -**គត** គុ. នៅហើយក្នុងទីស្ងាត់, ទៅហើយក្នុងទីស្ងាត់ ។

**រាគ** បុំ. [ រញ្ជ+ណ ] សេចក្ដីត្រេកអរ, តម្រេក, រាគៈ; វិ. **រញ្ជនំ> រាគោ** ។ -**កទ្ទមាទិ** គុ. (ភក់) មានភក់គឺរាគៈជាដើម ។ -**កន្តារាទិ** គុ. (កន្តារៈ) មានកន្តារៈគឺរាគៈជាដើម ។ -**អគ្គិ** បុំ. ភ្លើងគឺរាគៈ ។ -**តណ្ហា** ឥ. តណ្ហាដ៏សម្បយុត្តដោយរាគៈ ។ -**ទរថ** បុំ. សេចក្ដីក្រវល់ក្រវាយគឺរាគៈ, សេចក្ដីក្រវល់ក្រវាយដោយអំណាចនៃរាគៈ ។ -**ទោសមោហពន្ធន** នបុំ. ចំណងគឺ..., គ្រឿងចងគឺ... ។ -**ទោសមោហមានទិដ្ឋិសង្គ** បុំ. ធមិជាគ្រឿងជំពាក់គឺ... ។ -**បដិឃាត** គុ. កិ.បន្ទោបង់នូវរាគៈ, កិ.កម្ចាត់បង់នូវ... ។ -**រជាទិ** គុ. (ធូលី) មានធូលីគឺរាគៈជា

Websites: WatKhemaraRatanaram.org or WatKhmers.org

ដើម ។ . **សង្កាទិ** គុ. (កិលេសជាគ្រឿងជំពាក់) មានកិលេសជាគ្រឿងជំពាក់គឺរាគៈជាដើម ។

**រាគាទិ** គុ. [ រាគ+អាទិ ] មានរាគៈជាដើម ។ . **កិលេសគហណ** នបុំ. កិ.ស្មុគ្រស្មាញដោយកិលេសមានរាគៈជាដើម ។ . **និមិត្ត** នបុំ. និមិត្តមានរាគៈជាដើម ។ . **បណិធិ** បុំ. កិលេសជាគ្រឿងតាំងនៅមានរាគៈជាដើម ។ . **ភេទ** គុ. ផ្សេងដោយកិលេសមានរាគៈជាដើម ។ . **វិគមន** នបុំ. ជាទីទៅប្រាសនៃកិលេសមានរាគៈជាដើម ។

**រាគាភិភូត** គុ. [ រាគ+អភិភូត ] គឺរាគៈគ្របសង្កត់ហើយ ។

**រាជ** បុំ. [ រាជ+អរ ឬរញ្ជ+ណ ] អ្នករុងរឿងដោយសម្បត្តិផ្សេងៗឬអ្នកញាំងមហាជនអោយត្រេកអរចំពោះខ្លួនដោយសង្គហវត្ថុ៤យ៉ាង (ព្រះរាជា, ស្តេច); វិ. **នានាសម្បត្តីហិ រាជតិ ទិព្វតិ ចិរោចតីតិ> រាជា, ចតូហិ សង្គហវត្ថូហិ អត្តនិ មហាជនំ រញ្ជេតីតិ វា> រាជា** ។ . **កកុធភណ្ឌ** នបុំ. ភណ្ឌៈដ៏ឧត្តមសមគួរដល់ព្រះរាជា, កកុធភ័ណ្ឌសម្រាប់ព្រះរាជា ។ . **កោដ្ឋាគារ** បុំ. ឃ្លាំងនៃព្រះរាជា ។ . **អង្គណ** នបុំ. ព្រះលាននៃព្រះរាជា ។ . **និវេសន** នបុំ. ព្រះរាជនិវេសន៍, ដំណាក់នៃព្រះរាជា ។ . **បរិវដ្ដ** ឥ. កិ.វិលទៅជុំវិញនៃព្រះរាជា (វង្សនៃព្រះរាជា) ។ . **បីឡ** នបុំ. កិ.បៀតបៀននៃព្រះរាជា, កិ.រឹបជាន់អំពីព្រះរាជា ។ . **ភជី** បុំ. ជនដែលព្រះរាជាចិញ្ចឹមហើយ, អាមាត្យនៃព្រះរាជា ។ . **ភាវ** បុំ. ភាវៈនៃ...ជាព្រះរាជា ។ . **មហាមត្ត** បុំ.

Websites: WatKhemaraRatanaram.org or WatKhmers.org

មហាមាត្យនៃព្រះរាជា, អាមាត្យធំនៃព្រះរាជា ។ - **មាន** ន. គ្រឿងរាប់នៃព្រះរាជា, រង្វាស់នៃព្រះរាជា ។ - **មុទ្ទា** ឥ. ត្រានៃព្រះរាជា (ព្រះរាជលញ្ឆករ) ។ - **មុទ្ទិកា** ឥ. ព្រះទំរង់នៃព្រះរាជា, ចិញ្ចៀននៃព្រះរាជា ។ - **យុវរាជសេនាបតិអាទិ** គុ. (ឥស្សរជន) មានព្រះរាជានិងព្រះយុវរាជនិងសេនាបតីជាដើម ។ - **ហំស** ពុំ. រាជហង្ស, ស្ដេចហង្ស ។

**រាជាណា** ឥ. [ រាជ+អាណា ] អាជ្ញានៃព្រះរាជា, អំណាចនៃព្រះរាជា ។

**រាជាធិបតី** ពុំ. [ រាជ+អធិបតី ] ព្រះរាជាទ្រង់ជាអធិបតី, ព្រះរាជាជាធំ ។

**រាជាមច្ច** ពុំ. [ រាជ+អមច្ច ] អមាត្យនៃព្រះរាជា ។

**រាជារហ** គុ. [ រាជ+អរហ ] គួរដល់ព្រះរាជា ។

**រាជិនី** ឥ. [ រាជ+ឥនី ] ព្រះរាជិនី, ស្ដេចស្រី ។

**រាជុបដ្ឋាន** នពុំ. [ រាជ+ឧបដ្ឋាន ] ទីជាទីបម្រើនូវព្រះរាជា, ទីជាទីគាល់នូវព្រះរាជា ។

**រាសិ** ពុំ. [ រស+ឥ ] គំនរ ។ - **មត្ថក** ពុំ. ទីបំផុតនៃគំនរ ។

**រាហុគ្គហិត** គុ. [ រាហុ+គហិត ] គឺរាហូចាប់ហើយ ។

**រាហុល** វ.ន. ព្រះរាជកុមារឈ្មោះរាហុល ។ - **មាតា** ឥ. មាតានៃព្រះរាហុល ។

**វិត្ត** គុ. [ វិច+ត ] សូន្យ, ទទេ ។

**រុក្ខ** ពុំ. [ រុហ+ខ, ហ>ក ] ឈើ, ដើមឈើ (វិ. **រុហតីតិ> រុក្ខោ**) ។

Websites: WatKhemaraRatanaram.org or WatKhmers.org

- ក្ខន្ធ ពុំ. ដើមនៃឈើ, គំនរនៃឈើ ។ - ចេត្យានិ នបុំ. ដើមឈើជាចេតិយ ។ - ឆាយា ឥ. ម្លប់នៃឈើ, ស្រមោលនៃឈើ ។ - ពចាទិ គុ. រុក្ខាវយវៈមានសំបកនៃឈើជាដើម ។ - ទេវតា ឥ. ទេវតាអ្នកស្ថិតនៅឫសដើមឈើ ។ - បណ្ណ នបុំ. ស្លឹកនៃឈើ ។ - បទរ នបុំ. រនាបជាវិការនៃឈើ (រនាបឈើ) ។ - មូល នបុំ. គល់ឈើ, ទីជិតនៃឈើ ។ - សាខា ឥ. មែកនៃឈើ ។ - សុសិរ ពុំ. ប្រហោងនៃឈើ ។

រុក្ខាឡ្ហក ពុំ. [ រុក្ខ+អាឡ្ហក ] ឃ្នាបជាវិការៈនៃឈើ, ឃ្នាបឈើ ។

រុច្ចតិ កិ. [ រុច+យ+តិ_វ. ] គាប់ចិត្ត, ពេញចិត្ត; គឺ... គាប់ចិត្ត,... ។

រុច្ចន នបុំ. [ រុច+យ+យុ ] ជាទីគាប់ចិត្ត (សេចក្តីគាប់ចិត្ត, វិ. រុចិយ-តេតិ> រុច្ចនំ) ។ - ដ្ឋាន នបុំ. ទីជាទីគាប់ចិត្ត ។

រុចិ កិ. [ រុច+អ+ឦ-អជ្ជ. ] គាប់ចិត្តហើយ, ពេញចិត្តហើយ ។ ន.ឥ. សេចក្តីគាប់ចិត្ត, សេចក្តីពេញចិត្ត; វិ. រុច្ចនំ> រុចិ ។ ប្រែថា ពន្លឺ, រស្មី ក៏បាន ។

រុចិរ គុ. [ រុច+ឥរ ] ល្អ, រុងរឿង (វិ. រោចតីតិ> រុចិរំ) ។

រុជ្ជតិ កិ. [ រុជ+យ+តិ_វ. ] ចាក់, ចាក់ដោត, ឈឺចាប់ ។

រុជនក គុ. [ រុជ+យុ+ក_សកត្ថ ] ចាក់ដោត, ឈឺចាប់ ។

រុទំ គុ. [ រុទន្ត+សិ_វិ., ន្ត+សិ_វិ>អំ ] កាលយំ, កំពុងយំ ។

រុទន្ត គុ. [ រុទ+អន្ត ] កាលយំ, កំពុងយំ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**រុទមាន** គុ. [ រុទ+មាន ] កាលយំ, កំពុងយំ ។

**រុហតិ** កិ. [ រុហ+អ+តិ.វ. ] ដុះ, ដុះឡើង,... ។

**រុហិរុប្បាទកម្ម** នថុំ. [ រុហិរ+ឧប្បាទ+កម្ម ] កម្មគឺកិ.ញុំាងព្រះលោហិតឱ្យកើតឡើង ។

**រូប** នថុំ. [ រូប+អ ] ធម្មជាតតែងវិនាស (រូប); វិ. **រុប្បតីតិ> រូបំ** ។ **-ក្ខន្ធ** ថុំ. កងនៃរូប, គំនរនៃរូប ។ **-គត** គុ. ដល់ហើយនូវរូប ។ **-គរុក** គុ. អ្នកធ្ងន់ក្នុងរូប ។ **-តណ្ហា** ឥ. តណ្ហាអាស្រ័យនូវរូប ។ **-ប្បមាណិក** គុ. អ្នកមានប្រមាណក្នុងរូប, ... ។ **-មទនិម្មទន** នថុំ. កិ.ញុំាញីនូវសេចក្ដីស្រវឹងក្នុងរូប ។ **-មទមត្តភាវ** ថុំ. ភាវៈនៃ...ជាអ្នកស្រវឹងហើយដោយ សេចក្ដីស្រវឹងក្នុងរូប ។ **-សម្បត្តិ** ឥ. សម្បត្តិនៃរូប, កិ.ដល់ព្រមដោយរូប ។ **-សម្បុណ្ណ** គុ. សម្បូណ៌ដោយរូប, ពេញព្រមដោយរូប ។ **-សិរី** ឥ. សិរីនៃរូប ។ **-សោភគ្គប្បត្ត** គុ. ដល់ហើយនូវភាវៈនៃ...ជាស្រីមានចំណែកល្អដោយរូប, ដល់ហើយនូវលំអនៃរូបដ៏លើស, -ដ៏ប្រសើរ ។

**រូបក** នថុំ. [ រូប+ក ] រូបតូច, រូបប្រៀប ។

**រូបី** គុ. [ រូប+ឦ ] មានរូប; វិ. **រូបំ យស្ស អត្ថីតិ> រូបី** ។

**រេ** និ. រ៉ឺ, រ៉ឺយ, អាកំហូច, មេកំហូច, អាចង្រៃ, មេចង្រៃ, ហ៊ីយអានេះ, ហ៊ីយមេនេះ,... ។

**រេណុ** ថុំ. ឬ នថុំ. [ រិ+ណុ, ឥ នៃរិ>ឯ ] លំអង, ធូលី (វិ. **រេតិ បសវេ.**

គីតិ> វេណុ) ។

**រោគ** បុំ. [ រុជ+ណ, ជ>គ ] សភាវៈតែងចាក់ដោត, ឈឺចាប់ (រោគៈ); វិ. **រុជតីតិ> រោគោ** ។ - **តិកិច្ឆន** នបុំ. កិ.រក្សានូវរោគ, កិ.ព្យាបាលនូវរោគ ។ - **និឌ្ឍ** គុ. លំនៅនៃរោគ, ជាលំនៅនៃរោគ ។ - **ភយ** នបុំ. ភ័យគឺរោគ, ភ័យអំពីរោគ ។

**រោចេសិ** កិ. [ រុច+ណេ+សិ_វ. ]. គាប់ចិត្ត, ពេញចិត្ត ។

**រោទតិ** កិ. [ រុទ+អ+តិ_វ. ] យំ, ទួញយំ ។

**រោទាមិ** កិ. [ រុទ+អ+មិ_វ. ] យំ, ទួញយំ ។

**រោទន្ត** គុ. [ រុទ+អន្ត ] កាលយំ, កំពុងយំ។

**រោទន្តី** គុ. [ រុទ+អន្ត,ចុះឦ_ឥ. ] កាលយំ, កំពុងយំ ។

**រោទន** នបុំ. [ រុទ+យុ ] កិ.យំ; វិ. **រុទិយតេតិ> រោទនំ** ។ - **បត្ត** គុ. ដល់ហើយនូវកិ.យំ ។ - **បរាយន** គុ. មានកិ.យំជាទីប្រព្រឹត្តទៅក្នុងខាងមុខ; វិ. **រោទតិ ឯត្ថាតិ> រោទនំ; រោទនំ បរាយនំ អស្សាតិ> រោទនបរាយនោ** ។

**រោបេតិ** កិ. [ រុប+ណេ+តិ_វ. ] ដាំ, បណ្តុះ ។

**រោបាបេន្តិ** កិ. [ រុប+ណាបេ+អន្តិ_វ. ] ឲ្យដាំ, ឲ្យបណ្តុះ ។

**រោបេត្វា** អ. [ រុប+ណេ+ត្វា ] ដាំហើយ, បណ្តុះហើយ ។

**រោបិត** គុ. [ រុប+ឥ_អា.+ត ] គឺ...ដាំហើយ, បណ្តុះហើយ ។ - **ត្តា** ព្រោះភាវៈនៃស្វាយនោះជាឈើគឺ...ដាំហើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**រោសេន្ត** គុ. [ រុស+ណោ+អន្ត ] កាលខឹង, កាលក្រោធ,... ។

**រោហិតមច្ឆ** ចុំ. [ រោហិត+មច្ឆ ] ត្រីឆ្កិន ។ **រសទាន** នចុំ. កិ.ឱ្យនូវរសនៃត្រីឆ្កិន ។ . **រសភោជន** នចុំ. ភោជនដ៏លាយដោយរសនៃត្រីឆ្កិន, ភោជនប្រកបដោយរសនៃត្រីឆ្កិន ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**លក្ខ** នបុំ. [ លក្ខ+អ ] វត្ថុជាគ្រឿងកំណត់ (ខ្នាច់, គ្រឿងសម្គាល់, ស្លាម, តំនូស); វិ. **លក្ខេ ឯកេនាតិ> លក្ខំ** ។ . **យោគ្គ** នបុំ. កិ.ប្រកបនូវខ្នាច់ (យោគ្គ ប្រែថា យាន ក៏បាន ) ។

**លក្ខណ** នបុំ. [ លក្ខ+យុ ] ធម្មជាតជាគ្រឿងកំណត់ (គ្រឿងសំគាល់, ស្លាម, តំនូស, លក្ខណៈ); វិ. **លក្ខេ អនេនាតិ> លក្ខ-ណំ** ។ . **មន្ត** បុំ. មន្តសម្រាប់ទាយនូវលក្ខណៈ ។ . **មន្ត-កុសលតាយ** ព្រោះភាវៈនៃខ្លួនជាស្រីឈ្លាសក្នុងមន្តសម្រាប់ទាយនូវលក្ខណៈ ។ . **វិចិត្ត** វិចិត្រដោយលក្ខណៈ ។ . **សម្បន្នវិចនមត្ត** គុ. អាការៈត្រឹមតែពាក្យដែលដល់ព្រមហើយដោយលក្ខណៈ ។

**លក្ខណានុព្យញ្ជនប្បដិមណ្ឌិត** គុ. [ លក្ខណានុព្យញ្ជន+បដិមណ្ឌិត ] ប្រដាប់ហើយ ដោយលក្ខណៈនិងអនុព្យញ្ជនៈ ។

**លក្ខណាហត** គុ. [ លក្ខណ+អាហត ] មានគ្រឿងសម្គាល់គឺបុគ្គលបៀតបៀនទូទៅហើយ, មានគ្រឿងសម្គាល់ត្រាទុកហើយ, -ដៅទុកហើយ ។ **អាហត**<អា+ហន+ត ។

**លក្ខណូបនិជ្ឈាន** នបុំ. [ លក្ខណ+ឧបនិជ្ឈាន ] កិ.ចូលទៅសម្លឹងនូវលក្ខណៈ ។

**លកុណ្ឌក** គុ. [ លកុដិ+អ, ចុះក-សកត្ថ ] តឿ ។ . **ភទ្ទិយត្ថេរ** បុំ. ព្រះថេរៈឈ្មោះលកុណ្ឌកភទ្ទិយៈ, ព្រះថេរៈឈ្មោះភទ្ទិយៈតឿ ។

**លគ្គ** គុ. [ លគ្គ+អ ] ជាប់, ចំពាក់, ទើរ ។ . **ចិត្ត** គុ. មានចិត្តជាប់

WAT KHEMARARATANARAM

Websites: WatKhemaraRatanaram.org or WatKhmers.org

ហើយ ។ - មានស គុ. មានចិត្តជាប់នៅហើយ ។

លគ្គតុ កិ. [ លគ្គ+អ+តុ_ប ] ចូរជាប់, ចូរទើរ,... ។

លគ្គន្តិ កិ. [ លគ្គ+អ+អន្តិ_វ. ] ជាប់, រមែងជាប់ ។

លគ្គាបេយ្យ កិ. [ លគ្គ+ណាបេ+ឯយ្យ_ស. ] គប្បីញុំាង...ឱ្យជាប់, គប្បី ឱ្យជាប់ចំពាក់ ។

លគ្គិ កិ. [ លគ្គ+អ+ឦ_អជ្ជ. ] ជាប់ហើយ, ទើរហើយ ។

លគ្គិត្វា អ. [ លគ្គ+ឥ_អា. +ត្វា ] ជាប់ហើយ, ទើរហើយ,... ។

លច្ឆសិ កិ. [ លភ+អ+សិ_វ., ភ>ច្ឆ ] បាន ។

លច្ឆាមិ កិ. [ លភ+អ+ស្សាមិ_ភ., ភ>ច្ឆ, លុបស្ស ] នឹងបាន ។

លជ្ជតិ កិ. [ លជ្ជ+អច្ចលជ+យ+តិ_វ. ] អៀន, ខ្មាស ។

លជ្ជា ឥ. [ លជ្ជ+អ+អា_ឥ. ] សេចក្ដីអៀន, សេចក្ដីខ្មាស ។

លជ្ជាបិត គុ. [ លជ្ជ+ណាបេ+ឥ_អា.+ត ] ឱ្យខ្មាសហើយ, គឺ...ឱ្យខ្មាស ហើយ ។

លជ្ជាបេសិ កិ. [ លជ្ជ+ណាបេ+សិ_វ. ] ឱ្យខ្មាស, ញុំាង...ឱ្យខ្មាស ។

លជ្ជិត គុ. [ លជ្ជ+ឥ_អា.+ត ] គឺ...ខ្មាសហើយ, អៀនហើយ ។

លជ្ជិត្វា អ. [ លជ្ជ+ឥ_អា.+ត្វា ] ខ្មាសហើយ,អៀនហើយ ។

លជ្ជិតព្វ កិ. [ លជ្ជ+ឥ_អា.+តព្វ ] គឺ...គប្បីខ្មាស, ... ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**លជ្ជី** គុ. [ លជ្ជា+ឦ ] អ្នកមានសេចក្ដីខ្មាស; វិ. លជ្ជា យស្ស អត្ថិតិ> លជ្ជី ។ ឥត្ថីលិង្គ លជ្ជិនី ។

**លញ្ឆ** នបុំ. [ លញ្ឆ+អ ] សំណូក, កិ.ស្លូក ។ - **ការសទិស** គុ. ប្រាកដស្មើដោយកិ.ធ្វើនូវសំណូក ។

**លញ្ឆន្ត** គុ. [ លញ្ឆ+អន្ត ] កាលប្រថាប់ (កាលបោះត្រា) ។

**លញ្ឆាបេត្វា** អ. [ លញ្ឆ+ណាបេ+ត្វា ] ញ៉ាំងរាជបុត្រឱ្យប្រថាប់ហើយ, -ឱ្យបោះត្រាហើយ ។

**លដ្ឋិវនុយ្យាន** នបុំ. [ លដ្ឋិ+វន+ឧយ្យាន ] ឱទ្យានឈ្មោះលដ្ឋីវន, ឱទ្យានប្រកបដោយព្រៃដ៏ដេរដាសដោយដើមត្នោតជំទង់, -ត្នោតសាវ (សួននៃព្រៃត្នោតជំទង់ ។

**លដ្ឋិមធុក** នបុំ. [ លដ្ឋិ+មធុ+ក ] ឈើអែម, ឈើអែមវល្លិ (បាលីខ្លះថា **យដ្ឋិមធុក** ) ។

**លដុកិកា** ឥ. សត្វចៀបកប្បាស, សត្វប្រចៀច ។ - **ជាតក** នបុំ. ជាតកគឺបណ្ឌិតកំណត់ហើយដោយសត្វចៀបកប្បាស ។

**លណ្ឌ** នបុំ. គូថ, លាមក, អាចម៍ ។

**លតា** ឥ. [ លា+ត, លា>ល, ចុះអា_ឥ. ] វល្លិ ។

**លទ្ធ** កិ. [ លភ+ត ] គឺ...បានហើយ ។ - **កហាបណ** បុំ. កហា. បណៈដែលខ្លួនបានហើយ ។ - **កាល** បុំ. កាលនៃ...ដែលខ្លួនបានហើយ ។ - **គព្ភបរិហារ** គុ. មានបច្ច័យជាគ្រឿងរក្សានូវគភ៌

Websites: WatKhemaraRatanaram.org or WatKhmers.org

បានហើយ ។ . **ចីវរលាភក** ចុំ. លាភកដើម្បីចីវរគឺ...បាន ហើយ ។ ល ។

**លទ្ធព្វ** កិ. [ លភ+តព្វ ] គឺ...គប្បីបាន ។ ល ។

**លទ្ធាន** អ. [ លភ+ត្វា, ភ+ត្វា>យ>ទ្ធាន ] បានហើយ ។ **លទ្ធា,** **លទ្ធាយ** ចុះត្វាបច្ច័យដូចគ្នា ។

**លទ្ធិ** ឥ. [ លភ+តិ ] ដូចទិដ្ឋិ (វិ. **លភនំ ឋាននំ> លទ្ធិ**) ។

**លទ្ធុំ** អ. [ លភ+តុំ, តុំ>ទ្ធុំ, លុប ភ ] ដើម្បីបាន, កិ.បាន ។

**លទ្ធូបសម្បទ** គុ. [ លទ្ធ+ឧបសម្បទ ] អ្នកមានឧបសម្បទាបានហើយ ឬអ្នកមានឧបសម្ប័ទបានហើយ; វិ. **លទ្ធា ឧបសម្បទា យេន សោ> លទ្ធូបសម្បទោ** ។

**លបន្តិ** កិ. [ លប+អ+អន្តិ_វ. ] ពោល, និយាយ, ហៅរក ។

**លបាបេន្តិ** កិ. [ លប+ណាបេ+អន្តិ_វ. ] ឱ្យពោល, _ឱ្យនិយាយ, ... ។

**លភតិ** កិ. [ លភ+អ+តិ_វ. ] បាន ។

**លព្ភតិ** កិ. [ លភ+យ+តិ_វ. ] គឺ...បាន, _សំដៅ, _សង្កេតយក ។

**លព្ភា** កិ. [ លភ+យ+ឯយ្យ_ស. ] គប្បីបាន, គឺ... គប្បីបាន ។

**លភន្ត** គុ. [ លភ+អន្ត ] កាលបាន, កំពុងបាន ។

**លភន** នបុំ. [ លភ+យុ ] កិ. បាន; វិ. **លភិយតេតិ> លភនំ** ។ ជា ទីបាន; **លភតិ ឯត្ថាតិ> លភនំ** ។ . **ដ្ឋាន** នបុំ. ទីជាទី

Websites: WatKhemaraRatanaram.org or WatKhmers.org

បាន ។ - ភាវ ថុំ. ភាវៈគឺកិ.បាន, ភាវៈនៃកិ.បាន ។

**លភិតព្វ** កិ. [ លភ+ឥ_អា.+តព្វ ] គឺ...គប្បីបាន, -ត្រូវបាន ។

**លភិតព្វាលភិតព្វ** គុ. [ លភិតព្វ+អលភិតព្វ ] គឺ... គប្បីបាននិងមិនគប្បីបាន ។ - **យុត្តាយុត្តដ្ឋាន** នថុំ. ទីដែលខ្លួនគប្បីនិងទីដែលខ្លួនមិនគប្បីបាន និងទីគួរនិងទីមិនគួរ ។

**លភិតុំ** អ. [ លភ+ឥ_អា.+តុំ ] ដើម្បីបាន, វិកិ.បាន ។

**លភិស្សតិ** កិ. [ លភ+អ+ឥ_អា.+ស្សតិ_ភ. ] នឹងបាន ។

**លភេថ** កិ. [ លភ+អ+ឯថ_ស.] គប្បីបាន ។

**លលាដ** នថុំ. ថ្ងាស ។

**លសី** ឥ. ខួរក្នុងសន្លាក់ ។

**លហុ, លហុំ** គុ. ឬ កិវិ. ស្រាល, រហ័ស, ឆាប់ ។ - **ចិត្ត** គុ. អ្នកមានចិត្តរហ័ស ។ - **បរិវត្តក** គុ. ប្រព្រឹត្តទៅរហ័ស, ប្រែប្រួលរហ័ស ។ - **ភាវ** ថុំ. ភាវៈនៃ...ជារបស់រហ័ស ។

**លាជ** ថុំ. [ លាជ+អ ] លាជ ។ - **បញ្ចម** គុ. មានលាជជាគម្រប់ប្រាំ ។ - **បញ្ចមកបុប្ផ** នថុំ. ផ្កាមានលាជជាគម្រប់ប្រាំ ។

**លាបេស្សាមិ** កិ. [ លុ+ណាបេ+ស្សាមិ_ភ. ] នឹងឱ្យច្រូត, -ឱ្យកាត់ ។

**លាពុ, លាពុក, លាវុក** នថុំ. [ លម្ព+ឧ ] ឃ្លោក, ផ្លែឃ្លោក ។

**លាភ** ថុំ. [ លភ+ណ ] ទ្រព្យធមិដែលបុគ្គលតែងបាន (លាភ); វិ.

Websites: WatKhemaraRatanaram.org or WatKhmers.org

**លព្ភតីតិ**> **លាភោ** ។ កិ.បាន; វិ. **លភន្តិ**> **លាភោ** ។ - **អគ្គប្បត្ត** គុ. ដល់ហើយនូវលាភដ៏លើស, មានលាភដ៏លើសដល់ហើយ, ដល់ហើយនូវភាវៈជាអ្នកលើសដោយលាភ ។ - **អគ្គ-យសគ្គប្បត្ត** ដល់ហើយនូវលាភដ៏លើសនិងយសដ៏លើស, មានលាភដ៏លើសនិងយសដ៏លើសដល់ហើយ, ដល់ហើយនូវភាវៈជាអ្នកលើសដោយលាភនិងភាវៈជាអ្នកលើសដោយយស។ - **តណ្ហា** ឥ. សេចក្ដីប្រាថ្នាក្នុងលាភ, តណ្ហាអាស្រ័យនូវលាភ ។ - **សក្ការ** បុំ. លាភនិងសក្ការៈ (**សក្ការ**< ស+ករ+ណ = បច្ច័យដែលបុគ្គលធ្វើដោយប្រពៃ; វិ. **សុដ្ឋុ ករិយតីតិ**> **សក្ការោ**) ។ - **សក្ការាទិសុខ** នបុំ. សុខដែលកើតអំពីវត្ថុមានលាភនិងសក្ការៈជាដើម ។ - **សក្ការាភិភូត** គុ. គឺលាភនិងសក្ការៈគ្របសង្កត់ហើយ ។ - **សក្ការនិស្សិត** គុ. អាស្រ័យហើយនូវ... ។ - **សក្ការហត្ថ** គុ. មានលាភនិងសក្ការៈក្នុងដៃ; វិ. **លាភសក្ការា ហត្ថេសុ យេសំ តេ**> **លាភសក្ការហត្ថា** ។

**លាភាលាភ** នបុំ. [ លាភ+អលាភ ] លាភនិងមិនមានលាភ ។

**លាភុប្បាទក** គុ. [ លាភ+ឧ+បទ+ណ្វុ ] អ្នកញុំាងលាភឱ្យកើតឡើង; វិ. **លាភំ ឧប្បាទេតីតិ**> **លាភុប្បាទកោ** ។

**លាភុប្បាទនប្បដិបទា** ឥ. [ លាភ+ឧប្បាទន+បដិបទា ] បដិបទាជាហេតុញុំាងលាភឱ្យកើតឡើង ។

**លាភូបនិសា** ឥ. [ លាភ+ឧបនិសា ] បដិបទាជាទីចូលទៅអាស្រ័យនូវលាភ, បដិបទាដែលចូលទៅអាស្រ័យនូវលាភ, មានលាភជាដែន

Websites: WatKhemaraRatanaram.org or WatKhmers.org

ចូលទៅរកស្រ័យ ។

**លាមក** គុ. [ លា+មក ឬលម+ណ្វុ ] លាមក, ថោកទាប, អាក្រក់ ។. **លាភិ គណ្ហាតិ ហីនភាវចន្តិ> លាមកោ ។ - ពរ** គុ. លាមកជាង, លាមកវិសេស ។ - **ធម្ម** ចុំ. ធម៌ដ៏លាមក; គុ. មានធម៌ដ៏លាមក ។

**លាយន** នចុំ. [ លុ+យុ ] កិ.ច្រូត, កិ.កាត់, កាលជាទីច្រូត, កាលជាទីកាត់ ។

**លាយនគ្គ** គុ. [ លាយន+អគ្គ ] មានជាចំណែកគឺបុគ្គលគប្បីឱ្យក្នុងកាលជាទីច្រូត, មានដ៏ប្រសើរគឺបុគ្គលគប្បីឱ្យក្នុងកាលជាទីច្រូត ។

**លាយាបេស្សាមិ** កិ. [ លុ+ណាបេ+ស្សាមិ_ភ. ] នឹងញុំាង...ឱ្យច្រូត ។

**លាលា** ឥ. [ លា+អល, ចុះអា_ឥ. ] ទឹកមាត់ ។

**លិក្ខាបេត្វា ឬ លិខាបេត្វា** អ. [ លិក្ខ ឬលិខ+ណាបេ+ត្វា ] ញុំាង...ឱ្យសរសេរហើយ, -ឱ្យឆ្លាក់ហើយ ។

**លិក្ខិត្វា ឬ លិខិត្វា** អ. [ លិក្ខឬលិខ+ឥ_អា.+ត្វា ] សរសេរហើយ, ឆ្លាក់ហើយ ។

**លិច្ឆវី** អ.ន. ស្តេចលិច្ឆវី, ព្រះចៅលិច្ឆវី (ពួកជនដែលមានស្បែកជិតស្និទ្ធល្អព្រោះភាពជាអ្នកមានសម្បុរថ្លៃដ៏ល្អិត, រ. **សុខមច្ចនិកាយ លីនា អបាកដា ឆវិយោ យេសំ តេ> លិច្ឆវី**)

**លិម្បតិឬលិប្បតិ** កិ. [ លិប+អ+តិ_វ., ចុះនិ.អា. ] លាប, ប្រូក, ជាប់, ទើរ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**លិម្បាបេសិ** កិ. [ លិប+ណាបេ+ឍ្យ-អជ្ជ., ចុះនិ..អា, +ស.អា. ] ឱ្យលាបហើយ, ឱ្យប្ញកហើយ,... ។

**លិម្បិត្វា** អ. [ លិប+ឥ-អា.+ត្វា, ចុះនិ.អា. ] លាបហើយ, ប្ញកហើយ,... ។

**លិឡ្ហា ឬលីឡ្ហា** ឥ. កិ.យាងយាស, កិ.កែក្រាយ, លំនាំ (វេវ. លិលា) ។

**លុញ្ចន្ត** គុ. [ លុញ្ច+អន្ត ] កាលដក, កាលចោល ។

**លុញ្ចាបេតុំ** អ. [ លុញ្ច+ណាបេ+តុំ ] កិ.ញ៉ាំង...ឱ្យដក, ... ។

**លុញ្ចិត្វា** អ. [ លុញ្ច+ឥ-អា+ត្វា ] ដកហើយ,... ។

**លុញ្ចិស្សុ** កិ. [ លុញ្ច+អ+ឪ-អជ្ជ. ] ដកហើយ,... ។

**លុទ្ទក** ចុំ. [ លុធ+ទ, ធ>ទ, ចុះក.ស. ] អ្នកបៀតបៀន, ព្រាន, នាយព្រាន ។ - **និវាសនដ្ឋាន** នចុំ. ទីជាទីនៅនៃព្រាន ។

**លុទ្ធ** ចុំ., នចុំ. [ លុភ+ត ] អ្នកជាប់ជំពាក់, អ្នកល្មោភ, អំពើអាក្រក់ ។

**លូខ** គុ. សៅហ្មង (អាក្រក់, គ្រុដាបគ្រុជួស) ។ - **ជីវិត** នចុំ. ជីវិតដ៏សៅហ្មង, កិ.រស់នៅដ៏សៅហ្មង ។ - **ទាន** នចុំ. មានដ៏សៅហ្មង ។ - **ប្បសន្ន** គុ. អ្នកជ្រះថ្លាហើយក្នុងវត្ថុដ៏សៅហ្មង ។ - **ប្បមាណិក** គុ. អ្នកមានប្រមាណក្នុងសេចក្តីសៅហ្មង, ប្រកបដោយប្រមាណក្នុងវត្ថុដ៏សៅហ្មង ។ - **បាវុរណ** គុ. មានសំពត់សម្រាប់ដណ្តប់ដ៏សៅហ្មង ។

**លេឌ្ឌុ** ចុំ. [ លេឌ្ឌ+ឧ ] ដុំដី ។ - **ទណ្ឌាទិ** គុ. (បហុរណវត្ថុ) មានដុំដីនិងកំណាត់ឈើ (ឬដំបង) ជាដើម ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**លេណឬលេន** នថុំ. [ លិ+យុ ] (ទី) ជាទីពួន, ជាទីជ្រនកោន, លេណដ្ឋាន, គុហា; វិ. **និលីយន្តិ អស្មិន្តិ> លេណំ** ។ **- ទ្វារ** នថុំ. ទ្វារនៃគុហា ។ **- បព្ភារ** ថុំ. ញកនៃគុហា ។

**លោក** ថុំ. [ លុជ+ណ, ជ>ក ] សភាវៈតែងវិនាស (លោក); វិ. **លុជ្ជ-តីតិ> លោកោ** ។ **- ខាណុ** នថុំ. ដង្កត់នៃលោក ។ **- គរុ** ថុំ. អ្នកធ្ងន់ក្នុងលោក ។ **- ជេដ្ឋ** គុ. ទ្រង់ប្រសើរបំផុតក្នុងលោក, -ជាចម្បងក្នុងលោក ។ **- អត្ថចរិយា** ឥ. កិ.ប្រព្រឹត្តិជាប្រយោជន៍ដល់លោក ។ **- ធម្ម** ថុំ. ធម៌ប្រព្រឹត្តទៅតាមនូវលោក, លោកធម៌ ។ **- អន្តទស្សី** គុ. អ្នកមានកិ. ឃើញនូវទីបំផុតនៃលោកជាប្រក្រតី; វិ. **លោកស្ស អន្តំ បស្សិតុំ សីលម-ស្សាតិ> លោកន្តទស្សី** ។ **- នាថ** គុ. ព្រះពុទ្ធជាទីពឹងនៃលោក ។ **- និស្សរណសំខាត** គុ. ពោលគឺធម៌ជាគ្រឿងរលាស់ចេញចាកលោក ។ **- និស្សិត** គុ. អាស្រ័យហើយនូវលោក ។ **- បាល** ថុំ. អ្នករក្សានូវលោក ។ **- វឌ្ឍន** គុ. អ្នកញុំាងលោកឱ្យចម្រើន ។ **- វោលោកន** នថុំ. កិ.រមិលមើលនូវលោក, កិ. ត្រួតនូវលោក ។

**លោកានុកម្បក** គុ. [ លោក+អនុកម្បក ] អ្នកអនុគ្រោះនូវលោក, -ដល់សត្វលោក ។

**លោកាមិស** ថុំ. [ លោក+អាមិស ] អាមិសៈក្នុងលោក ។

**លោកិយ** គុ. [ លោក+ឥយ ] កើតក្នុងលោក, មានក្នុងលោក, លោកិយ; វិ. **លោកេ ជាតោ> លោកិយោ, លោកេ ភវោ**

Websites: WatKhemaraRatanaram.org or WatKhmers.org

ទា> លោកិយោ ។ . អភិញ្ញា ឥ. អភិញ្ញាជាលោកិយ ។ . កុដុម្ព នថុំ. សម្បត្តិ (ទ្រព្យ) ជាលោកិយ ។ . កុដុម្ពស្សា-មិនី គុ. ជាម្ចាស់នៃសម្បត្តិជាលោកិយ ។ . លោកុត្តរសម្បន្ន គុ. អ្នកដល់ព្រមហើយដោយប្រាជ្ញាជាលោកិយៈនិងលោកុត្តរៈ ។ . លោកុត្តរវិសេស ថុំ. គុណវិសេសជាលោកិយៈ និងលោកុត្តរៈ ។

លោកុត្តរ គុ. [ លោក+ឧ+តរ+អ, ត>ត្ត ] (ធម៌) ឆ្លងឡើងចាកលោក ឬឆ្លងឡើងហើយចាកលោក; វិ. លោកតោ ឧត្តរតីតិ> លោកុត្តរោ, លោកតោ ឧត្តិណ្ណោតិ ទា> លោកុត្តរោ ។ . ទាយជ្ជ នថុំ. ទ្រព្យជាមត៌កជាលោកុត្តរៈ, ភាវៈនៃ...ជាទាយាទនៃទ្រព្យជាលោកុត្តរៈ (ទាយជ្ជ<ទាយាទ+ណ្យ = ភាវៈនៃបុគ្គលអ្នកកាន់យកនូវទ្រព្យជាមត៌ក, ភាវៈនៃអ្នកកាន់យកនូវទ្រព្យដែលមាតានិងបិតាគប្បីឱ្យ; វិ. ទាយំ អាទទាតីតិ> ទាយាទោ, ទាយាទស្ស ភាវោ> ទាយជ្ជំ ) ។

លោណ នថុំ. [ លុ+យុ ] អំបិល, វត្ថុមានរសប្រៃ វិ. លុនាតិ ឆិន្ទតីតិ សេទំ ឆិន្ទតិ ស្វរសភាវំ ភវោតីតិ> លោណំ) ។ . សក្ខរា ឥ. ដុំនៃអំបិល ។ . អម្ពិលសេវនត្ថ ថុំ. ប្រយោជន៍ដល់កិ.សេពនូវវត្ថុមានរសប្រៃនិងវត្ថុមានរសជូរ ។

លោណកាទិភេទ នថុំ. [ លោណកាទិ+ភេទ ] ផ្សេងដោយវត្ថុមានវត្ថុមានរសប្រៃជាដើម; វិ. លោណកំ អាទិ យស្ស តំ> លោណកាទិ (វត្ថុ) ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**លោភ** បុំ. [ លុភ+ណ ] កិ.ជាប់, កិ.ជំពាក់, លោភៈ; វិ. **លុព្ភនំ> លោភោ** ។ - **ចោរ** បុំ. ចោរគឺសេចក្តីលោភ ។ - **ធម្ម** បុំ. ធម៌គឺសេចក្តីលោភ ។

**លោភាទិក្កិលេសជយ** បុំ. [ លោភ+អាទិ+កិលេស+ជយ ] កិ.ឈ្នះនូវកិលេសមានលោភៈជាដើម ។

**លោម** បុំ. ឬ នបុំ. [ លុ+ម ] រោម (វិ. **ចឡ្ហមានានំ លូយតេតិ> លោមោ**) ។ - **គណនា** ឥ. កិ.រាប់នូវរោម ។ - **ហដ្ឋជាត** គុ. មានកិ.ព្រឺនៃរោមកើតហើយ ។ - **ហំស** បុំ. កិ.ព្រឺនៃរោម ។

**លោហ** នបុំ. [ លុ+ហ ] លោហៈ (ជាតិដែកជាដើម) វិ. **លុនាតិ ឯតេនាតិ> លោហំ** ។ - **កុម្ភី** ឥ. ឆ្នាំងឬខ្ទះជាវិការៈនៃលោហៈ, នរកឈ្មោះលោហកុម្ភី ។ - **គុឡ** បុំ. ដុំនៃលោហៈ ។ - **ជាល** នបុំ. បណ្តាញជាវិការៈនៃលោហៈ, បណ្តាញគឺបុគ្គលធ្វើហើយដោយលោហៈ ។ - **នាឡិ** ឥ. នាឡិឬចំពូយជាវិការៈនៃលោហៈ ។ - **ភាជនសទ្ទ** បុំ. សូរនៃភាជនៈជាវិការៈនៃលោហៈ ។

**លោហមយ** គុ. [ លោហ+មយ ] ជាវិការៈនៃលោហៈ, គឺបុគ្គលធ្វើហើយដោយលោហៈ ។

**លោហិត** ន. ឬ គុ. [ រុហ+ឥ.អា.+ត, រ>ល ] ឈាម, ក្រហម (វិ. **រុហតិ សរីរេ ព្យាបនចសេនាតិ> លោហិតំ**) ។ - **គន្ធ** បុំ. ក្លិននៃឈាម ។ - **ចន្ទន** នបុំ. ចន្ទន៍ក្រហម ។ - **ធារា** ឥ. ចនៃឈាម ។ - **នទី** បុំ. មេទឹក (ស្ទឹង) គឺឈាម, ឈាមដូចជាស្ទឹង ។ - **បក្ខន្ទិកាពាធ** បុំ. អាពាធប្រកបដោយកិ.ស្ទុះទៅនៃ

Websites: WatKhemaraRatanaram.org or WatKhmers.org

ឈាម (អាពាធធ្លាក់ឈាម ឬចុះឈាម) ។ . **ភក្ខ** គុ. មានឈាមជាចំណី, .ជាភក្សាហារ ។ . **មក្ខិត** គុ. ប្រឡាក់ហើយដោយឈាម ។

**លោហិតក** គុ. [ លោហិត+ក ] ពណ៌ក្រហម, មានពណ៌ក្រហម ។

**លោឡុទាយី** អ.ន. ព្រះថេរៈឈ្មោះលោឡុទាយី ។ . **ត្ថេរវត្ថុ** នថុំ. រឿងនៃព្រះថេរៈលោឡុទាយី ។

# វ

**វ** និ. ពិត, មែន, តែប៉ុណ្ណោះ, គ្រាន់តែ, ត្រឹមតែ, ដដែល, ដូចដែល, តែម៉្យាង, ភ្លាម ។

**វក្ក** នបុំ. តម្រងបស្សាវៈ (តាមទម្លាប់ថា ទាច) ។

**វក្កលិ** អ.ន. ភិក្ខុឈ្មោះវក្កលិ ។

**វក្ខន្តិ** កិ. [ វច+អ+អន្តិ_វ, ច>ក ] ពោល, និយាយ, ស្តី ។

**វក្ខាមិ** កិ. [ វច+អ+ស្សាមិ_ភ., ច>ក, ស្សាមិ>ខាមិ ] នឹងពោល, នឹងនិយាយ, នឹងស្តី ។

**វគ្គ** បុំ. [ វជ+គ ] វគ្គ, ពួក, ក្រុម (វិ. **វជតិ សមូហត្តំ គច្ឆតីតិ> វគ្គោ**) ។

**វគ្គន្តិ** គុ. [ វគ+អន្ត ] កាលប៉ោក, កាលកញ្ឆ្រៀវ ។

**វគ្គពន្ធន** នបុំ. [ វគ្គ+ពន្ធន ] កិ.ចងគ្នាជាពួក, កិ.ចងនូវពួក ។

**វគ្គុគទ** គុ. [ វគ្គុ+គទ ] មានវាចាដ៏ពីរោះ, ព្រះអង្គមានព្រះវាចាដ៏ពីរោះ ។

**វគ្គុមុទាតីរិយ** គុ. [ វគ្គុមុទា+តីរ+ឥយ ] អ្នកនៅទៀបឆ្នេរនៃស្ទឹងឈ្មោះវគ្គុមុទា, វិ. **វគ្គុមុទាតីរេ វសន្តីតិ> វគ្គុមុទាតីរិយា** ។

**វគ្គុលិវត្ត** គុ. [ វគ្គុលិ+វត្ត ] អ្នកមានវត្តដូចជាសត្វប្រជៀវ, អ្នកមានវត្តដូចជាវត្តនៃសត្វប្រជៀវ ។

**វង្ក** គុ. [ វង្ក+អ ] វៀច, កោង (វិ. **វំកតីតិ>វង្កោ** ។ . **គោ_បានសិរិនទ្ធ** គុ. ចងត្របែងដោយបង្កង់ផ្ទះដ៏វៀច, ចងរឹតដោយ... ។ . **សណ្ឋាន** នបុំ. សណ្ឋានដ៏វៀច, ទ្រង់ទ្រាយដ៏

វៀច ។

**វង្គន្ត** អ.ន. ព្រាហ្មណ៍ឈ្មោះវង្គន្តៈ ។

**វង្គីស** អ.ន. ព្រាហ្មណ៍ឈ្មោះវង្គីសៈ ។

**វច្ឆកុដិ** ឥ. [ វច្ឆ+កុដិ ] កុដិសម្រាប់បន្ទោនូវវច្ឆៈ (ឈាមក, អាចម៍), បង្គន់ ។

**វច្ចកូប** បុំ. [ -+កូប ] រណ្ដៅនៃវច្ចៈ, បង្គន់ ។

**វច្ឆ** បុំ. កូនគោ ។

**វច្ឆតរ** បុំ. កូនគោឈ្មោល ។

**វច្ឆតរី** ឥ. កូនគោញី ។

**វចន** នបុំ. [ វច+យុ ] ពាក្យ, សម្ដី (វិ. **វុច្ចតេតិ> វចនំ, វុច្ចតិ ឯតេនាតិ> វចនំ, វត្តព្វន្តិ> វចនំ**) ។ - **ក្កម** បុំ. លំដាប់នៃពាក្យ ។ - **ក្ខម** បុំ. កិ.អត់ធន់នូវពាក្យ ។ - **ការិកា** ឥ. អ្នកធ្វើនូវពាក្យ, អ្នកធ្វើតាមពាក្យ ។ - **បដិវចន** នបុំ. ពាក្យនិងពាក្យតប, ពាក្យតបនូវពាក្យ ។ - **មត្ត** តុ ហេតុគ្រាន់តែពាក្យ, -សព្វបើពាក្យ ។ - **សមនន្តរ** តុ. កាលជាលំដាប់ស្មើនៃពាក្យ ។

**វចនាវសាន** នបុំ. [ វចន+អវសាន ] កាលជាទីបំផុតចុះនៃពាក្យ, -ជាទីចប់នៃពាក្យ, កាលជាទីអវសាននៃពាក្យ ។

**វចី** ឥ. [ វច+អ+ឦ.ឥ. ] វាចាជាហេតុគឺបុគ្គលពោល (វាចា, ពាក្យ, សំដី); វិ. **វុច្ចតិ ឯតាយាតិ> វចី** ។ - **ករណមត្ត** តុ.

Websites: WatKhemaraRatanaram.org or WatKhmers.org

ហេតុគ្រាន់តែគិ.ធ្វើនូវវាចា, -នូវសំដី ។ - **ទុច្ចរិត** នបុំ. កិ. ប្រព្រឹត្តិអាក្រក់ដោយវាចា ។ - **បកោប** បុំ. កិ. កម្រើកដោយវាចា ។ - **សច្ច** នបុំ. សេចក្តីពិតដោយវាចា ។ - **សុចរិត** នបុំ. កិ. ប្រព្រឹត្តល្អដោយវាចា ។

**វចោ** ន. [ វច+អំ_វិ.>វចោ ] នូវពាក្យ, នូវសំដី(បែបនេះមានប្រើដោយតិច) ។

**វជ** បុំ. [ វជ+អ ] ប្រទេសជាទីទៅដើម្បីប្រយោជន៍ដល់គិ.នៅអាស្រ័យនៃគោ (ក្រោល); វិ. **វជន្តិ យំ គាវោ និវាសនត្ថាយាតិ> វជោ** ។ - **ទ្វារ** បុំ. ទ្វារនៃក្រោល ។ - **ទ្វារមជ្ឈ** តុ. កណ្តាលនៃទ្វារនៃក្រោល ។

**វជន្តិ** កិ. [ វជ+អ+អន្តិ_វ. ] ទៅ, ដល់ ។

**វជាមិ** កិ. [ វជ+អ+មិ_វ. ] ទៅ, ដល់ ។

**វជាហិ** កិ. [ វជ+អ+ហិ_ប. ] ចូរទៅ, ចូរដល់ ។

**វជ្ជ** នបុំ. ឬ បុំ. [ វជ្ជ+អ ] អកុសលធម៌គឺបុគ្គលគប្បីវៀរ(ទោស), វិ. **វជ្ជេតព្វោតិ> វជ្ជោ** ។ វជ្ជ<វទ+អ, វទ>វជ្ជ = ប្រែថា «ពោល, និយាយ» វិ. **វទិយតេតិ> វជ្ជំ** ។ - **ទស្សី** តុ. អ្នកមានគិ.ឃើញនូវទោសជាប្រក្រតី, វិ. **វជ្ជំ បស្សិតុំ សីលមស្សាតិ > វជ្ជទស្សី** ។ - **មតី** តុ. អ្នកមានគិ. ដឹងនូវទោស, អ្នកមានគិ.ដឹងថាមានទោស ។

**វជ្ជន្តិ** កិ. [ វទ+អ+អន្តិ_វ., វទ>វជ្ជ ] ពោល, និយាយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**វជ្ជានុរូប** គុ. [ វជ្ជ+អនុរូប ] ដ៏សមគួរដល់ទោស ។

**វជ្ជាហិ** កិ. [ វទ+អ+ហិ_ប., វទ>វជ្ជ ] ចូរពោល, ចូរនិយាយ ។

**វជ្ជី** អ.ន. ជនវជ្ជី, ដែនវជ្ជី ។ - **បុត្តក** នបុំ. កូននៃជនវជ្ជី ។ - **វជ្ជី** នបុំ. ដែនវជ្ជី ។

**វជ្ជេត្វា** អ. [ វជ្ជ+អ+ត្វា ] វៀរហើយ, ចៀសវាងហើយ ។

**វជ្ជេតព្វ** កិ. [ វជ្ជ+អ+តព្វ ] គឺ...គប្បីវៀរ,... ។ - **យុត្តក** គុ. គួរគឺ... គប្បីវៀរ ។

**វជ្ឈប្បត្ត** គុ. [ វជ្ឈ+បត្ត ] ដល់ហើយនូវកិ. សម្លាប់, ដល់ហើយនូវទោសគឺបុគ្គលគប្បីសម្លាប់ (វជ្ឈ<ហន+ណ្យ, ហន>វធ, ធ>ឈ = វិ. **ហន្តព្វោតិ> វជ្ឈោ**) ។

**វជិរ** នបុំ. ឬ បុំ. [ វជ+ឥរ ] (រតនៈ) មានដំណើរគឺអ្វីនីមួយកម្ចាត់មិនបាន (ពេជ្រ); វិ. **វជតិ ន បដិហញ្ញតេ យស្ស គមនំ កេនចីតិ> វជិរំ** ។ - **អត្តិខិណញ្ញាណ** គុ. មានញាណដ៏មុតដូចជាចុងនៃពេជ្រ ។ - **នាឡិ** ឥ. នាឡិនៃពេជ្រ ។ - **ផាល** បុំ. ផាលជាវិការៈនៃពេជ្រ ។ - **ហត្ថ** គុ. មានពេជ្រក្នុងដៃ, វិ. **វជិរំ ហត្ថេ យស្ស សោ> វជិរហត្ថោ** ។

**វញ្ចនចិត្ត** នបុំ. [ វញ្ចន+ចិត្ត ] ចិត្តជាគ្រឿងលលួង, -ជាគ្រឿងបញ្ឆោត ។

**វញ្ចិត** គុ. [ វញ្ច+ឥ_អា.+ត ] បញ្ឆោតហើយ, លួងលោមហើយ ។

**វញ្ចិយមាន** គុ. [ វញ្ច+ឥ_អា. +យ+មាន ] គឺ...កាលបញ្ឆោត,...។

Websites: WatKhemaraRatanaram.org or WatKhmers.org

# វ

**វញ្ចេត្វា** អ. [ វញ្ចុ+អ+ត្វា ] បញ្ឆោតហើយ,... ។

**វញ្ចេស្សាមិ** កិ. [ វញ្ចុ+អ+ស្សាមិ_ភ. ] នឹងបញ្ឆោត,... ។

**វញ្ឈា** គុ. [ ហន+អ+អា_ឥ., ហន>វធ, ធ>ឈ+និ_អា. ] អា, ស្រីអា ស្រីឥតកូន ។

**វញ្ឈិត្ថី** ឥ. [ វញ្ឈា+ឥត្ថី ] ស្រីអា ។

**វដ្ដ** នបុំ. [ វត្ត+អ, ត្ត>ដ្ដ ] ធម្មជាតប្រព្រឹត្តទៅ (វិល, មូល, ស្បៀង, ចំណែក, មានជាចំណែក, ជ្រៃ, ឬជ្រៃក្រឹម, (វដ្ដៈ)); វិ. **វត្ត-តីតិ> វដ្ដំ** ។ - **អទ្ធា** ផ្លូវវែងគឺវដ្ដៈ, ផ្លូវឆ្ងាយគឺវដ្ដៈ ។ - **ទុក្ខ** នបុំ. ទុក្ខក្នុងវដ្ដៈ ។ - **មូលក** គុ. មានវដ្ដៈជាមូល ។ - **រុក្ខ** បុំ. ដើមជ្រៃក្រឹម ។ - **សន្ធិ** ឥ. ទីត គឺវដ្ដ, តំណ គឺវដ្ដៈ ។

**វដ្ដកា** ឥ. [ វដ្ដ+ណ្វុ+អា_ឥ. ] សត្វចាប, សត្វក្រួច ។

**វដ្ដានុគត** គុ. [ វដ្ដ+អនុគត ] ទៅតាមហើយនូវវដ្ដៈ ។

**វដ្ដិ** ឥ. [ វដ្ដ+ឥ. ] ប្រឆេះ, កណ្ដាប់, ខ្នាញ់ ។

**វដ្ដេតិ** កិ. [ វដ្ដ+ណេ+តិ_វ. ] ការ, មូរ, ឱ្យវិល ។

**វដ្ដេត្វា** អ. [ វដ្ដ+ណេ+ត្វា ] ការហើយ, មូរហើយ, ឱ្យវិលហើយ,... ។

**វឌ្ឍកី** [ វឌ្ឍ+ក+ឦ ] ជាងឈើ (វិ. **វឌ្ឍយតិ ឆិន្ទយតីតិ> វឌ្ឍកី**) ។

**វឌ្ឍតិ** កិ. [ វឌ្ឍ+អ+តិ_វ. ] ចម្រើន, រុងរឿង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

វឌ្ឍមាន គុ. [ វឌ្ឍ+មាន ] កាលចម្រើន, កំពុងចម្រើន ។ - កច្ឆាយាយ ក្នុងវេលាមានស្រមោលកំពុងចម្រើន ។

វឌ្ឍយិស្សុ កិ. [ វឌ្ឍ+ណយ+ទំ.អជ្ជ. ] ចម្រើនហើយ, ឱ្យចម្រើនហើយ ។

វឌ្ឍិត គុ. [ វឌ្ឍ+ឥ.អា.+ត ] ចម្រើនហើយ, គឺ....ចម្រើនហើយ ។ - អត្តានំ គុ. មានខ្លួនចម្រើនហើយ, មានខ្លួនអប់រំហើយ ។ - ត្តា ព្រោះភាវៈនៃទារកនោះជាអ្នកចម្រើនហើយ, ព្រោះភាវៈនៃ...ជាអ្នកចម្រើនហើយ ។

វឌ្ឍេត្វា អ. [ វឌ្ឍ+ណេ+ត្វា ] ចម្រើនហើយ, ឱ្យចម្រើនហើយ ។

វឌ្ឍេយ្យ កិ. [ វឌ្ឍ+ណេ+ឯយ្យ.ស. ] គប្បីចម្រើន, គប្បីឱ្យចម្រើន ។

វណ បុំ. [ វណ+អ ] ដំបៅ; ឧ. សរីរំ វណាយតិ ទិចុណ្ណតិ ឆិទ្ទាវច្ឆិទ្ទំ ភវតីតិ> វណោ ។ - បដិកម្មត្ថាយ ដើម្បីប្រយោជន៍ដល់កិ.ធ្វើតបនូវដំបៅ, -ដល់កិ.បំបាត់នូវដំបៅ ។

វណកាទិ គុ. [ វណក+អាទិ ] (ទោស) មានប្រជ្រុយជាដើម ។

វណ្ដ ឬ វណ្ដិក នបុំ. [ វដិ+ក, លុបក, ចុះនិ.អា. ] ទង, សណ្ដង់, ដង ឧ. ពន្ធិយតេ អនេនាតិ> វណ្ដំ ។ - មាលាទិភេទ គុ. ផ្សេងដោយផ្កាមានផ្កាកម្រងប្រកបដោយទងជាដើម ។

វណ្ណ បុំ. [ វណ្ណ+អ ] ពណ៌, សម្បុរ, គុណគឺបុគ្គលគប្បីសរសើរ, -គប្បីពណ៌នា, រស្មី, ភេទ, ត្រកូល, ជាតិ, អក្សរ ។ - គន្ធ បុំ. ពណ៌និងក្លិន ។ - គន្ធសម្បន្ន គុ. ដល់ព្រមហើយដោយពណ៌និងក្លិន ។ - ធាតុ ឥ. ធាតុគឺរស្មី ។ - បោក្ខរតាយ ដោយភាវៈនៃ...ជា

Websites: WatKhemaraRatanaram.org or WatKhmers.org

អ្នកមានសម្បុរដូចជាផ្កាឈូក, ដោយភាវៈនៃ...ជាអ្នកមានសរីរៈប្រកបដោយវណ្ណៈ ។ . **ភណានអវណ្ណភណានវស** ចុំ. អំណាចនៃកិ.ពោលនូវគុណគឺបុគ្គលគប្បីពណ៌នា និងកិ.ពោលនូវទោសគឺបុគ្គលមិនគប្បីពណ៌នា ។ . **ភេទ** ចុំ. ប្រភេទនៃពណ៌, សេចក្តីផ្សេងនៃពណ៌ ។ . **សណ្ឋានសម្បន្នអគន្ធកបុប្ផស-ទិស** គុ. ប្រាកដស្មើដោយផ្កាមិនមានក្លិនដែលបរិបូណ៌ដោយពណ៌និងទ្រង់ទ្រាយ ។

**វណ្ណយន្តិ** កិ. [ វណ្ណ+ណយ+អន្តិ.វ. ] ពណ៌នា, សរសើរ ។

**វណ្ណវន្តុ** គុ. [ វណ្ណ+វន្តុ ] មានពណ៌, វិ. **វណ្ណោ យស្ស អត្ថិ> វណ្ណវន្តុ** ។

**វណ្ណាទិ** [ វណ្ណ+អាទិ ] ធម៌មានវណ្ណៈជាដើម, វិ. **វណ្ណោ អាទិ យស្ស សោ> វណ្ណាទិ** (ធម្មោ) ។ ពហុ. វិ. **វណ្ណោ អាទិ យេសំ តេ> វណ្ណាទយោ** (ធម្មា) ។

**វណ្ណេត្វា** អ. [ វណ្ណ+ណេ+ត្វា ] ពណ៌នាហើយ, រៀបរាប់ហើយ, សរសើរហើយ ។

**វណ្ណេន្តិ** កិ. [ វណ្ណ+អ ឬណេ+អន្តិ.វ. ] ពណ៌នា, សរសើរ ។

**វណិជ្ជា** ឥ. [ វាណិជ+ណ្យ+អា..ឥ. ] កម្ម ឬ ការងាររបស់ពាណិជ (ជំនួញ, កិ.ជួញ), វិ. **វាណិជានំ កម្មំ> វណិជ្ជា** ។

**វត** និ. ឱ, ហ្ន៎, ឱហ្ន៎, យី, យីអើ, ទេតើ,... ។

**វត្ត** នចុំ. [ វត+ណ ឬវត្ត+អ ] កិច្ច ឬសេចក្តីប្រតិប័ទដែលបុគ្គលគប្បី

Websites: WatKhemaraRatanaram.org or WatKhmers.org

